# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំទី ២៥ ខែកុម្ភៈ លេខ ២

ព.ស. ២៤៩៥ – គ.ស. ១៩៥៣

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង


ផ្នែកសាសនា — ទំព័រ

— ព្រះពុទ្ធសាសនានៅប្រទេសបិន (តចប់) លោក ប៉ាយ-ប៊ុក ........ ៨៣

— ប្រភេទសាសនកថា .......... ព្រះមហា ទេព-ប៉ោ ...... ៩០

— រឿងកុណ្ឌលកេសីថេរី (តចប់) ...... ព្រះមហាសុខុមាលី-សេន ... ៩៩

ផ្នែកអក្សរសាស្ត្រ

— ការបណ្ដុះនិស្ស័យ (តមក) ....... ព្រះមហាឧត្តមវិជ្ជា ប៊ុង-ប៉ម ... ១១៣

— រឿងសាមកុក (តមក) .......... ឧកញ៉ា ទូ-កន ......... ១១៨

— រឿងអាវ៉ក្សថ្លែងរឿងម្ភៃប្រាំ (តមក) ... លោក ប៉ាយ-ប៊ុក......... ១២៣

— រឿងស្លាប់ព្រោះជាតិ (តមក) ........ លោក គង់-លឹម. ........ ១៣០

— រឿងប៉ូលនឹងវីរ៉ស៊ីនី (តមក) ........ លោក ដេង-ជ្រីវ ........ ១៣៦

— សកម្មភាពនៃក្រុមជំនុំទំនៀមទម្លាប់ស្រុកខ្មែរ ពុទ្ធសាសនបណ្ឌិត្យ ១៤១

កំណត់ទីនប្រវត្តិការណ៍

— សន្និសិទព្រះពោធិវ័ង្ស ហួត-តាត អំពី សមាជសាកលលើកទី ២ នៃពុទ្ធសាសនា. ពុទ្ធសាសនបណ្ឌិត្យ ....... ១៤៨

— សុន្ទរកថាបណ្ឌិតម៉ាល៉ាល៉ះសេកេរៈថ្លែងក្នុង សមាជសាកលលើកទី ២ នៃពុទ្ធសាសនា ពុទ្ធសាសនបណ្ឌិត្យ. ........ ១៥៣

— បញ្ជីរាយនាមចៅអធិការដែលតាំងថ្មី (តមក) ក្រសួងធម្មការ .......... ១៥៩


មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃជារ ១៩២រ. ០០

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

## TABLE DES MATIÈRES


### PARTIE RELIGIEUSE

| | | Pages |
|---|---|---|
| — Le Bouddhisme en Chine (suite et fin) ........ | *M. Ray-Buc* .......... | 83 |
| — Sasanakatha ........ | *Brah Maha Tep-Po* ...... | 90 |
| — Histoire de Neang "KUNDALA-KESITHERI" (suite et fin).... | *Preah Maha SUKHUMALI-SEN* | 99 |

### PARTIE LITTERAIRE

| | | |
|---|---|---|
| — Education morale (suite)..... | *Vén. Pœung-Pam* ..... | 113 |
| — Histoire de SAMBOK (suite) . | *Oknha Nou-Kan* ....... | 118 |
| — Les vingt cinq récits du Mauvais Génie (suite) ... ..... | *M. Ray-Buc* .......... | 123 |
| — Mort pour la patrie (suite) ... | *M. Kong-Lim* ......... | 130 |
| — Paul et virginie (suite) ...... | *M. Phéng-Chrieu* ........ | 136 |
| — L'activité de la commission des Mœurs et Coutumes..... | *institut Bouddhique* ..... | 141 |

### NOTES ET CHRONIQUES

| | | |
|---|---|---|
| — Conférence du Vén. Brah Bodhivangs HUOT-TATH sur le 2e Congrés Mondial Bouddhique | *Institut Bouddhique* ..... | 148 |
| — Discours du Dr MALALASEKERA au 2e Congrés Mondial Bouddhique ...... ....... | — — ...... | 153 |
| — Nomination des nouveaux Chau-adhikar (suite) ..... | *Ministère des Cultes* ....... | 159 |


Prix d'abonnement annuel (comprenant 12 numéros): 192$00

# ព្រះពុទ្ធសាសនានៅប្រទេសចិន

## លោកប៉ាយ-ប៊ុក ក្រមការ រៀបរៀង

(ត - ចប់)

---

## ៣)– ប្រទេសចិនតាំងពីលទ្ធិឡាម៉ាចូលមកស្ថិតនៅ រហូតមកដល់សព្វថ្ងៃនេះ

*ក)– សន្តតិវង្សមុង្គោល "យ៉ែន" ដល់ចុងសតវត្សទី ១២, ព្រះអធិរាជនៃប្រទេសចិនបានអញ្ជើញព្រះបាទសង់សីស្កាន់ នាយពួកមុង្គោលខាងលិច ឲ្យមកជួយធ្វើសង្គ្រាមនឹងពួកមុង្គោលខាងកើត ។ តែព្រះបាទសង់សីស្កាន់ ទៅជាទ្រង់វាយយកប្រទេសចិនទាំងមូលវិញ ហើយបានវាតកម្មិកភាព ក្នុងវិសាលភាព ៨០០ យោជន៍ ពីខាងកើតទៅខាងលិច ហើយ ១០០០ យោជន៍ ពីខាងជើងទៅខាងត្បូង ។*

*រដ្ឋាភិបាលមុង្គោល បានស្ថាបនានូវកល្បយុគចំពោះទៅលើសិទ្ធិត្រួតត្រាដែលគេហៅថា មជ្ឈមយុគនៃប្រទេសចិន ។ ពួកមុង្គោលជាអ្នកកាន់ព្រះពុទ្ធសាសនាពីមុនមកស្រាប់ ដល់បានចូលមកស្ថិតនៅប្រទេសចិន ក៏តាំងផ្សាយព្រះពុទ្ធសាសនាគ្រប់និគម, ជនបទ, ស្រុក, ខេត្ត ។*

*នៅក្នុងរដ្ឋកាលព្រះបាទគូប៊ីឡៃខ័ន ជាព្រះរដ្ឋទាយាទ តវង្សព្រះបាទសង់សីស្កាន់ ទ្រង់បានស្ថាបនានូវសន្តតិវង្សមុង្គោល "យ៉ែន"*

ព្រះវិហារព្រះអធិកដដែលសាងសម្រាប់បូជាប្រជាជាតិ ទៅជាសម្រាប់ធ្វើព្រះរាជពិធីខាងព្រះពុទ្ធសាសនា ។

ព្រះបាទគូប៊ីឡៃខ័ន ទ្រង់មិនបានបាត់កងទ័ពឲ្យទៅវាយប្រទេសជប៉ុន ដោយទ្រង់ព្រះតម្រិះថា ប្រទេសជប៉ុនជាប្រទេសកាន់ព្រះពុទ្ធ-សាសនា ។ ទ្រង់មានព្រះរាជបំណងនឹងយកប្រទេសនេះដោយសន្តិវិធី ហើយទ្រង់បានធ្វើព្រះរាជបុតហ្ញយទៅព្រះមហាក្សត្រនៃប្រទេសជប៉ុនថា: "ពួកសន្តបុគ្គលដែលយើងគោរពពោលថា: មនុស្សទាំងអស់ជាបងប្អូនសាច់ឈាមជាមួយ ហើយថាពិភពលោកគឺជាត្រកូលតែមួយ: ត្រូវតែប្រជារាស្ត្រទាំងអស់មានធម៌សាមគ្គី កុំប្រយោជន៍ច្បាប់ល្អមានប្រយោជន៍" ។

ដល់ចុងរជ្ជកាលដែលទ្រង់សោយរាជ្យ, ទ្រង់បានបាត់ឲ្យគេធ្វើបញ្ជីចំរើនវត្តនឹងចំនួនព្រះសង្ឃ: ឃើញវត្តមានចំនួន ៤២.៨១៨ វត្ត, ព្រះសង្ឃមាន ២១៣.១៤៨ អង្គ ។

នៅក្នុងរជ្ជកាលព្រះបាទសង់ស៊ីស្មានព្រះរាជកំហុសធំបំផុត លំដាប់ពីការពេញព្រះទ័យចំពោះប្រាក់នឹងស្រ្តី គឺការអនុគ្រោះជាខ្លាំងដល់ពួកពុទ្ធសាសនិកជន មានការឧបត្ថម្ភពួកឡាម៉ាជាដើម ។

ពួកសន្តតិវង្ស "យ័ន" មានព្រះរាជបំណងចង់ស្ថាបនាខ្លួន "អធិ-ប្រទេសនៃពិភពលោក" ចុះនជាទ្រង់មានព្រះទ័យសន្តោស មិនត្រឹមតែ

ព្រះពុទ្ធសាសនា ថែមទាំងទទួលនូវគ្រិស្តសាសនា, ប្រពៃណីនៃប្រទេសដែលស្ថិតនៅក្នុងអធិស្សរភាពនឹងលទ្ធិឯទៀត ។ រហូតដល់វិទ្យាល័យមហាម័តបំពោះពួកតុគេខាងលិច ។ ព្រះសន្តតិវង្សនេះ ជាមេនយោបាយយ៉ាងឯក ។

តែសង្គ្រាមពលរដ្ឋ ដោយការតស៊ូនឹងព្រះសង្ឃខាងព្រះពុទ្ធសាសនា នឹងបណ្ឌិតខាងកុង-ហ្វូង-ស៊ី នាំឲ្យសន្តតិវង្សមុង្គោល ទៅជាថយគេជានុភាព ហើយនាំឲ្យវិនាសសាបសូន្យនៅ គ. ស. ១៣៦៨ ។

លំដាប់តមក, នៅសន្តតិវង្ស "មីង" ព្រះអធិរាជ១បត្តម្ពក "បណ្ឌិត" ហើយស្ថាបនា នូវគណៈសង្ឃមួយហៅថាៈ "គណៈរូ-វៃ គីយ៉ាវ" ។ គណៈនេះប្រែថាៈ "គណៈអកម្មភាព" ដែលរបនាពីព្រះពុទ្ធសាសនា ជនកបុរសគឺជនជាតិចិនម្នាក់នាមថាៈ "លូ-ត្សឹ ប្តូតាបស" "លូ" កើតនៅខេត្តស័ងទុង ។ លោកបានយកទៅថ្វាយព្រះអធិរាជនៃសន្តតិវង្ស "មីង" នឹង "ច័ង", នូវគម្ពីរប្រាំដែលពណ៌នាពីវគ្គ ៦ យ៉ាងគឺៈ

១ – ព្យាយាមឲ្យផុតពាកតណ្ហា

២ – ទួញសោកបំពោះពិភពលោក

៣ – បំបាត់នូវការកាន់ប្រឡំ

៤ – របនាចិត្តទៅកាន់ធម៌ពិត

៥ - ធ្វើឲ្យដូចក្អែកចាំ (សៀវភៅបញ្ជាក់ពីធម៌ផ្សេងៗ)

៦ – ប្រាជ្ញាធម្មជាតិធ្វើឲ្យបរិសុទ្ធ ស្អាតឲ្យដល់សុទ្ធភាព ។

១) - នៅសន្តតិវង្ស "ម៉ានជូ", ព្រះអធិរាជ "ស៊ុនជី" បានឧបត្ថម្ភព្រះពុទ្ធសាសនា តែព្រះរាជាយាងខាំងគី - កុងសោយរាជ្យពី គ.ស. ១.៦៦២ ទៅដល់ ១.៧២២ ទ្រង់បានទំនុកបំរុងតែពួក "បណ្ឌិត" ខាងកុង-ហ្វុង-ស៊ឺ ។

ដល់មក គ.ស. ១៨៤៨, មានការបះបោរពួក "តៃប៉ិង ឬ "សក់វែង" ។ ពួកនេះស្អប់ព្រះពុទ្ធសាសនា ហើយបង្កទៅជាសង្គ្រាមពលរដ្ឋជាអធិកអធម, ពិឃាដលោកសង្ឃជាច្រើន តែមិនធ្វើទារុណកម្មចំពោះពួកគ្រិស្តសាសនិកជន ។

ពួកតៃប៉ិងនេះបដិសន្ធិនៅខេត្តក្វាង-ស៊ី នៅទន្លេកន្តាំង, បានចូលទៅលុកលុយខេត្តឯទៀតខាងត្បូង ហើយបាននាំកងទ័ពទៅដល់ទីក្រុងណៀង-ស៊ុន ។ ក្នុងមួយឆ្នាំៗ ឥទ្ធិពលពួកតៃប៉ិងកាន់តែខ្លាំងឡើង ហើយចូលទៅលុកលុយខេត្តឯទៀតជាច្រើនតទៅទៀត, តែទទួលមានសង្គ្រាមបារាំងអង់គ្លេសនឹងចិន ពួកតៃប៉ិងក៏ផុតអានុភាព ក្នុងពេលនោះ (គ.ស. ១៨៤២) ។

## ៨ – ស្ថានភាពបច្ចុប្បន្ននៃព្រះពុទ្ធសាសនា នៅប្រទេសចិន

នៅប្រទេសចិនសព្វថ្ងៃ មានប្រជារាស្ត្រដោយភាគច្រើនកាន់ព្រះពុទ្ធសាសនា តែវត្តអារាម, ព្រះវិហារ បូជនិយដ្ឋានទាំងប៉ុន្មានសាងតាំងពីបុរាណកាលមានខ្លះបាក់បែក, បណ្ដាប្រជារាស្ត្រដែលជាពុទ្ធសាសនិកជនច្រើនតែស្ត្រី ។

ព្រះពុទ្ធសាសនាសព្វថ្ងៃក្លាយទៅជាលទ្ធិមួយបែបថ្មី គឺព្រហ្មវិហាររចនាទៅជារូបនិមិត្តមេត្តា, ករុណាត្រឡប់ទៅជាមានរូបនិមិត្តដែរ ដូចជារូប "ក្វាន-យីន" ។ នៅសន្តតិវង្សស៊ុង រូប "ក្វាន-យិន" ជារូបបុរស តែប្រហែល ៦០០ ឆ្នាំហើយ រូបព្រះពុទ្ធ "ក្វាន-យិន" គេបានផ្លាស់ជារូបស្ត្រីទៅវិញ គឺព្រះទេវធីតានៃមេត្តា, ករុណាទៅវិញ ។

ការស្រោចស្រង់មនុស្សដោយការសិក្សា មានសារៈសំខាន់ចំពោះព្រះពុទ្ធសាសនាប្រទេសចិន ។ ព្រះពុទ្ធរូបចិន គឺ ពូ-សា, ក្វាន-យិន មានប្រតិស្ឋានព្រះរូបជាសាមសិបពីររូប ។ មានព្រះពុទ្ធរូបខ្លះ មានព្រះហស្ត ១២ គូ ដែលជាបដិមារូបសម្រាប់ដឹកនាំពួកល្ងង់ និងពួកប្រព្រឹត្តបាបអកុសល ។ ព្រះរូបទាំងសាមសិបពីរនេះ អាចយាងទៅកាន់ព្រះរាជអាណាចក្រផ្សេងៗ ដើម្បីនឹងសំដែងធម្មទេសនាចំពោះមនុស្សសត្វនៅស្ថានសួគ៌, ស្ថានកាមគត, រូបគត, អរូបគត ។ សេចក្ដីមេត្តា

នៃព្រះរូបសាមសិបពីរនេះ អាចរចនាព្រះមហាក្សត្រ, ចៅហ្វាយខេត្ត, មន្ត្រី, ប្រជារាស្ត្រ, ឲ្យបានចរិយាល្អ ហើយមានវិធីស្រោចស្រង់ជាច្រើនបែប យ៉ាង មានអានុភាពទៅជួយអ្នកដទៃបាន, ដោយសុត្រធម៌ព្រមទាំងធ្វើសមាធិ, ការពារនូវគ្រោះកាចចង្រៃឧបទ្រព, អាយុវែង, ព្រះនិព្វាន ។

បើតាមពណ៌នាខាងលើ, ព្រះពុទ្ធ "ក្វាន យិន" គឺមានអានុភាពជាងព្រះពុទ្ធទាំងអស់ ព្រះពុទ្ធ ពូ ហៀន, ម័នជុស្រី ។ ការដែលធ្វើរូបព្រះពុទ្ធ "ក្វាន-យិន" ជារូបស្ត្រីមកពីគំនិតប្រជាមានិត ។

ព្រះពុទ្ធ ពុស្សៀន និង វេង ស៊ូ គេឆ្លាក់ព្រះរូបជាព្រះពុទ្ធពីបុរាណ សម្រាប់ជួយព្រះសក្យមុនីពុទ្ធ ។

ព្រះពុទ្ធ វេង-ស៊ូ ព្រះអាទិទេពខាងគតិបណ្ឌិត បានយកសឹង្ហជាបដិមារូបខាងពលភាព ជាព្រះពជយាន, ព្រះពុទ្ធ ពូ-ហៀន, ព្រះអាទិទេពនៃសកម្មភាព បានយកដំរី ជាបដិមារូបខាងអប្បមាទ, មិនធ្វេសប្រហែស ។

ព្រះពុទ្ធសាសនានៅប្រទេសចិន គឺយកគុណធម៌នឹងម.រិជាបដិមារូប ហើយរចនាទៅជាព្រះពុទ្ធរូបឲ្យគេគោរព; ចំពោះការហែសព មានពិធីព្រះពុទ្ធសាសនាលាយឡំជាមួយផង, ផ្សាយនូវមេត្តាចំពោះសត្វតិរច្ឆាន, មេត្តាចំពោះមនុស្សជាតិ, ល. . . ។

ចំណែកខាងព្រះសង្ឃកាន់វិន័យមិនសូវត្រឹមត្រូវទេ, មានអាស្រមយាយជីជាច្រើន តែយាយជីទាំងនេះ មិនមានវិន័យរឹងប៉ឹង ចូលចេញដើរលេងតាមអំពើចិត្ត ។

មានពួកឫសីនៅប្រចាំវត្តអារាម ឬបូជនីយដ្ឋាន; មានខ្លះនៅក្នុងគុហាភ្នំ ឬនៅក្នុងអាស្រមមួយ ។

គេមានឃើញនៅប្រទេសចិន ពួកឡាម៉ាលឿងខាងក្រមកែទម្រង់ត្រង់-កប: ហើយនឹងពួកឡាម៉ាប្រឆេះខាងក្រមបុរាណមិនសូវជ្រះថ្លា, កាន់វិន័យមិនសូវតឹងរឹង ហើយចូលទៅរួបរួមជាមួយព្រះសង្ឃ ‘ ហ្វូអ៊ីស្ត ” ដែលទើបនិមន្តជាបឋមមកកាន់ប្រទេសចិន, មុនសន្តតិវង្សម៉ុងគោល ។

# ប្រភេទសាសនកថា

## ព្រះមហា ទេព-ប៉ោ វត្តកែវព្រះភ្លើង ក្រុងភ្នំពេញ

ទេសនាតាមវិទ្យុឃោសនសព្ទនៃប្រទេសកម្ពុជា ក.លពីថ្ងៃ ៨ កើតខែមិគសិរ
ឆ្នាំជូតសំរឹទ្ធិស័ក ព. ស. ២៤៩១ (៩-១២-៤៨)

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

សូមថ្វាយបង្គំចំពោះព្រះភគវន្តមុនី អរហំសម្មាសម្ពុទ្ធ (ព្រមទាំងព្រះធម៌និងព្រះអរិយសង្ឃ) ។

ឱកាសនេះ អាត្មាភាពសូមសំដែងធម្មទេសនា តាមប្រភេទសាសនាដ៏វិសេសដែលខ្ពស់ទាបជាងគ្នាជាលំដាប់ដូចតទៅនេះ:–

បណ្ដាសាសនាដែលមានក្នុងលោក និងរកសាសនាណាដែលអាចបង្អុលបង្ហាញនិងបង្រៀនទៅទឹកអម្រឹតគឺព្រះនិព្វាន ឲ្យស្រក់ស្រោចលើសន្តានចិត្តសត្វដែលកំពុងឆេះក្ដៅដោយភ្លើងទុក្ខភ្លើងកិលេស ឲ្យរលត់យ៉ាងឆាប់រហ័សដូចព្រះពុទ្ធសាសនានេះគ្មានឡើយ ។ ហេតុនេះបានជាព្រះពុទ្ធសាសនា ទទួលកិត្តិយសអំពីសំណាក់អ្នកប្រាជ្ញទាំងឡាយថាជាសាសនាយ៉ាងឯកឥតគូរប្រៀប ។

ព្រះបរមគ្រូជាម្ចាស់ទ្រង់ចេញចាកសក្យត្រកូលទៅទ្រង់ព្រះផ្នួសក្នុងព្រៃ ស្វែងរកធម៌ជាគ្រឿងរំលត់ទុក្ខដោយព្យាយាមយ៉ាងតឹងរ៉ឹង ដកប

ដល់បានសម្រេចនូវអនុត្តរសម្មាសម្ពោធិញ្ញាណ លុះត្រាស់ដឹងហើយ ទ្រង់មានព្រះទ័យពេញប្រៀបដោយព្រះមហាករុណាធិគុណ ទ្រង់ប្រ-ទានធម៌ ដែលព្រះអង្គត្រាស់ដឹងនោះ ដល់ទេវតានិងមនុស្សទាំងឡាយ ឲ្យបានសម្រេចប្រយោជន៍ក្នុងប្រភេទធម៌ទាំងបីនេះ គឺបរិយត្តិធម៌ ទ្រង់បន្ទូលបង្ហាញព្រះត្រៃបិដកទាំងបី ១, បដិបត្តិធម៌ ទ្រង់បន្ទូលបង្ហាញសីល សមាធិ បញ្ញា ១, បដិវេធធម៌ ទ្រង់បន្ទូលបង្ហាញដល់ការត្រាស់ដឹងនូវមគ្គនិងផល១ ។ ព្រះបរិយត្តិធម៌ជាមគ្គនាយក នាំមុខធម៌ទាំងពួង បើមិនរៀនបរិយត្តិជាមុនទេ មិនអាចនឹងធ្វើបដិបត្តិធម៌ឲ្យពេញបរិបូណ៌បានឡើយ ។ ហេតុនេះ កុលបុត្រអ្នកមានសទ្ធា ប្រាថ្នានឹងបំពេញ បដិបត្តិធម៌ឲ្យបានពេញលេញនោះ លុះតែរៀនបរិយត្តិធម៌ឲ្យដឹងវិធីចំរើនជាមុន ហើយសឹមបំពេញបដិបត្តិធម៌ជាក្រោយ, ព្រោះការរៀនបរិយត្តិធម៌ ទុកដូចជារៀនផែនទីរបស់បដិបត្តិធម៌ ឲ្យដឹងទិសដំបន់ និងជ្រុងជ្រោយនៃកិលេសធម៌ ការខំអប់រំបដិបត្តិធម៌ ឲ្យរឹងប៉ឹងល្អ ទុកដូចជាដើរតាមផែនទី ដែលបរិយត្តិធម៌បន្ទូលប្រាប់ស្រេចហើយ, ការបានសម្រេចមគ្គផលជាថ្នាក់ៗទុកដូចជាដំណាក់សម្រាប់អ្នកដំណើរ ឈប់សម្រាកក្នុងរយៈផ្លូវ, ការបានសម្រេចព្រះនិព្វាន ទុកដូចជាបានធ្វើដំណើរទៅដល់ស្រុកដែលសុខសាន្តត្រាណប្រាសចាកទុក្ខ ។

ពុទ្ធបរិស័ទឲ្យអ្នកមានបំណងចង់បំពេញបដិបត្តិធម៌ ដោយពេញបរិបូណ៌នោះ គួរស៊ូទ្រាំរៀនលុះត្រាតែបានសម្រេចវិជ្ជា ខាងផ្លូវបរិយត្តិធម៌ជាមុន ទើបធ្វើបដិបត្តិធម៌ឲ្យដើរត្រង់ផ្លូវបាន បើមិនធ្វើដូច្នេះទេមុខជានឹងដើរខុសផ្លូវវង្វេងភាន់ច្រឡំ ប្រតិបត្តិពានលើខុសសោះ តែប្រកាន់ថាត្រូវ ៗ ដូចមនុស្សពួកខ្លះមានជាតិជាបុថុជ្ជន នៅក្នុងអំណាចកម្មទំនុកបម្រុង ជួនបានសុខជួនបានទុក្ខ ក្នុងពេលដែលបានសុខ កុំអាលប្រញាប់សរសើរថាគល់ឈើដុំថ្មឲ្យសុខនោះ ឱកាសណាដែលត្រូវបានទុក្ខវិញ ក៏កុំប្រញាប់ដាក់ទោស ទៅលើខ្មោចបិសាចពេក គួរពិចារណាឲ្យឃើញហេតុផលសិន, សិរីសួស្តីឬអពមង្គលមិនមែនបានមកពីគល់ឈើឬដុំថ្មនោះទេ មនុស្សដែលជឿហេតុដទៃ ហើយបដិសេធផលកម្មពោលដូច្នេះ នឹងថាត់ថាជាអ្នកកាន់ព្រះពុទ្ធសាសនាឯណាបាន? ជនណាមួយដែលមានគំនិតជឿបែបនេះហើយ មុខជានឹងវង្វេងហែលវិលវល់ក្នុងឃោរលោហលោកនេះរកកោះត្រើយមិនឃើញ នឹងជួបប្រទះតែសេចក្តីអន្តរាយក្នុងរយៈផ្លូវជានិច្ចមិនខាន ៗ

អ្នកដំណើរដែលទៅតាមផ្លូវ ជើងទឹកជើងគោកក្នុងលោកនេះ រមែងជួបប្រទះប៉ះពារនឹងសត្រូវមានសត្វសាហាវយង់ឃ្នង នឹងចោរកំណាចចាំស្ទាក់ក្នុងទីស្ងាតក្បែររយៈផ្លូវ បៀតបៀនដណ្តើមយកធនធានឲ្យអ្នកដំណើរឬអន្តរាយទាំងជីវិតក៏សឹងមាន តែគេគិតប្រឌិតតាក់តែង ឲ្យកើត

មានយានជំនិះគ្រប់បែប មានទូករទេះយន្តហោះជាដើម សម្រាប់ប្រើក្នុងផ្លូវទឹក ផ្លូវគោក និងផ្លូវអាកាស ឲ្យលឿនទៅដោយកំលាំងយន្តចក្រនោះ ឲ្យស្ទុះរំលងតាកសេចក្តីអន្តរាយក្នុងផ្លូវ ទៅដល់ទីដែលគេប៉ុនប៉ងដោយសួស្តីបាន យ៉ាងណាមិញ; សត្តនិករទាំងឡាយដែលបណ្តែតក្នុងវដ្តសង្សារ ហើយតែងប៉ះប្រទះជួបនឹងសត្រូវគឺកិលេសទាំងឡាយមានតណ្ហា (ចំណង់) មានះ (សេចក្តីប្រកាន់) ទិដ្ឋិ (សេចក្តីឃើញខុស) ជាដើម ចាំរាំងរកស្កាត់ដំណើរចិត្តរបស់សត្វ ឲ្យទាក់ទាមយឺតយូរដំណើរ មិនឲ្យសម្រេចព្រះនិព្វានឆាប់រហ័សបាន វិលតែនឹងកើត ចាស់ ឈឺ ស្លាប់ ស្លាប់កើត កើតស្លាប់ វិលចុះវិលឡើង ជួនជាមនុស្ស ជួនជាសត្វមិនទៀងទាត់ប្រាកដ ទទួលសោយសុខតិច ទុក្ខច្រើនជានិច្ច ជានិរន្តរ៍រកទំនេរគ្មាន តែងងងឹត ងងល់វង្វេងវិលវល់ ហែលប៉ុងប៉ោងក្នុងសមុទ្រ ប៉ើមចុះប៉ើមឡើង រកកោះត្រើយមិនឃើញ ។

ព្រះបរមសាស្តាជាមហាអ្នកប្រាជ្ញយ៉ាងឆ្នើម ខាងផ្លូវសាសនា បានទ្រង់ខំប្រឹងរិះគិតពារកធម៌ល្អនឹងអាក្រក់ ដរាបដល់បានសម្រេចនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ហើយទ្រង់តែងតាំងធម្មយាន ជាយានយ៉ាងឯកក្នុងផ្លូវធម៌ឡើង ជាយានសម្រាប់ស្រង់ផ្ទុកនាំ ចំឡងសត្វទាំងឡាយ ដែលកំពុងលិចលង់ផុងវង្វេងក្នុងមហាសមុទ្រ គឺវដ្តសង្សារដែលជាទី មានក្រពើត្លាមមករពិន្ទុ គឺកិលេសដ៏ច្រើន ទ្រង់ចំឡង

រំលងទៅដាក់ដល់ត្រើយខាងនាយគឺព្រះនិព្វាន ជាស្ថានប្រាសចាកទុក្ខ សោកពេកភ័យចង្រៃអពមង្គល មិនឲ្យចូលមកបៀតបៀនបាន ក៏យ៉ាងនោះដែរ ។

មិនតែប៉ុណ្ណោះ ព្រះមហាករុណាធិគុណទ្រង់ទំរើងចង្អុលបង្ហាញប្រៀបធៀបផែនទីទុកឲ្យសត្វខាងក្រោយអ្នកចង់ធ្វើដំណើរ ទៅកាន់ព្រះនិព្វានថា: សម្មាទិដ្ឋិ (សេចក្ដីយល់ត្រូវ) ដូចជាប្រទីបសម្រាប់បំភ្លឺផ្លូវ; សម្មាសង្កប្បោ (សេចក្ដីត្រិះរិះត្រូវ) ដូចជាមគ្គុទ្ទេសក: អ្នកចង្អុលប្រាប់ផ្លូវ; សម្មាវាចា (សំដីត្រូវ) ដូចជាសាលាសំណាក់; សម្មាកម្មន្តោ (ការងារត្រូវ) ដូចជាផ្លូវថ្នល់ដ៏ស្អាតល្អ; សម្មាអាជីវោ (ការចិញ្ចឹមជីវិតត្រូវ) ដូចជាទីពលទំនេរឥតអ្វីជាប់ជំពាក់; សម្មាវាយាមោ (ការព្យាយាមត្រូវ) ដូចជាជំហានដែលឈានដើរទៅ; សម្មាសតិ (សេចក្ដីរលឹកត្រូវ) ដូចជាខ្យល់ដកដង្ហើមចេញចូល; សម្មាសមាធិ (ការដំកល់ចិត្តឲ្យនឹងក្នុងអារម្មណ៍ដ៏ត្រូវ) ដូចជាសេចក្ដីសុខដែលក្របានជួបប្រទះ ។ ផ្លូវទាំង៨នេះហើយដែលឈ្មោះថា "អរិយមគ្គ" ។ នេះឯងជាឧបាយបង្ហាញផ្លូវដ៏ប្រសើរ ធ្វើដំណើរចិត្តរបស់សត្វអ្នកប្រតិបត្តិធម៌ ឲ្យដល់នូវព្រះនិព្វានជាទីរលត់ទុក្ខព្រមគ្រប់យ៉ាងបាន ។

ព្រះពុទ្ធសាសនាដែលនឹងមានសន្ទុះលឿន រីកទៅកាន់សេចក្ដីចំរើនរុងរឿងបាន ដោយអាស្រ័យពួកពុទ្ធបរិស័ទទាំង ៤ គឺ ភិក្ខុ, សាមណេរ,

ឧបាសក, ឧបាសិកា, ខំប្រឹងស្រវាស្រទេញស្ទុះស្ទាព្យាយាម ស្ដាប់ធម៌ រៀនធម៌ ប្រតិបត្តិធម៌ ដោយក្ដីគោរពយ៉ាងហ្មត់ចត់ ទាំងខំប្រឹងបង្ហាត់បង្រៀនបរិយត្តិធម៌ ឲ្យបានចេះដឹងច្រើនគ្នាទឹងមានការប្រតិបត្តិធម្មវិន័យដោយសេចក្ដីព្រមព្រៀងគ្នា; ឯឧបាសកឧបាសិកាបរិស័ទ ក៏ចេះរក្សាសីល ៥ សីល ៨ ព្រមទាំងមានសទ្ធាជ្រះថ្លា ធ្វើទានដោយសេចក្ដីស្រុះស្រួល អាចធ្វើសប្បាយទាំង ៤ នេះ ឲ្យកើតឡើងគឺ សេនាសនសប្បាយ ចេះធ្វើកុដិសាលាវិហារជាដើម ជាទីនៅរៀនសូត្រស្រួលមិនលំបាក ១; បុគ្គលសប្បាយ មានឧបាសកទំនុកបម្រុងព្រមទាំងមានភិក្ខុសាមណេរផងគ្នាជាកល្យាណមិត្ត ជាគូប្រឹក្សាធម្មវិន័យច្រើនរូបមិនទាស់ទែងគ្នា ១; អាហារសប្បាយ បានអាហារគ្រប់គ្រាន់មិនខ្វះខាត ១; ធម្មសប្បាយ បានធម្មវិន័យ គម្ពីរដីកាក្បួនខ្នាតជាគ្រឿងរៀនសូត្រច្រើន ១ ៗ សប្បាយទាំងនេះបើកើតមានព្រមហើយអាចនឹងធ្វើ ឲ្យភិក្ខុសាមណេរ ខំប្រឹងសម្រឹងស្ទឹងស្ទាធ៍ធម្មវិន័យ ឲ្យមានជំរឿនស្ទុះទៅកាន់វឌ្ឍនធម៌ដោយឆាប់រហ័ស នឹងខំប្រឹងបួសបំពេញកិច្ចក្នុងព្រះពុទ្ធសាសនាដរាបដល់អស់ជីវិតបានផង; អស់លោកឧបាសកអ្នកទំនុកបម្រុង ក៏បានសម្រេចផលានិសង្សច្រើនជាអនេក ដូចពុទ្ធភាសិតថា:

សុខស្ស ទាតា មេធាវី សុខំ សោ អធិគច្ឆតិ

អ្នកមានប្រាជ្ញាបានឲ្យសេចក្ដីសុខដល់គេ តែងបានសេចក្ដីសុខនោះមកខ្លួនវិញ នេះឈ្មោះថាទំនុកបម្រុងក្នុងផ្លូវធម៌ ៗ

មិនត្រឹមតែផ្លូវធម៌ ទើបត្រូវអាស្រ័យសប្បាយទាំង៤យ៉ាងនោះឡើយ សូម្បីផ្លូវលោកក៏ត្រូវអាស្រ័យដូចគ្នា ទើបរីលទៅកាន់សេចក្ដីចំរើនទាន់សម័យបាន ហេតុនេះឃើញថា ការរៀបចំស្រុកទេសជាទីនៅរបស់មនុស្ស ឲ្យមានផ្ទះសំបែង គ្រឿងប្រដាប់សម្រាប់ប្រើប្រាស់ទឹងសំលៀកបំពាក់ តាក់តែងរាងកាយឲ្យសប្បាយសម្បូណ៌ហូរហៀរ រៀបរយសមរម្យល្អមើល ឲ្យមានអាហារសម្រាប់បរិភោគ មានយានជំនិះសម្រាប់ទៅមកដោយស្រួលមិនខ្វះប្រើ ឬខំប្រឹងបណ្ដុះបណ្ដាលបង្កើតក្បួនច្បាប់ ខាងអក្សរសាស្ត្រ ប្រវត្តិសាស្ត្រ ហត្ថកម្ម វេជ្ជកម្ម ផ្លូវគមនាគមន៍ជាដើម ឲ្យស្ទុះទៅកាន់វឌ្ឍនធម៌ដោយពេញបន្ទុក ទើបចុំចើងបាន បើប្រទេសមួយៗក្នុងលោកសន្និវាសនេះ មិនខំប្រឹងជ្រោងស្ទួយបង្កើតបង្កើននូវសប្បាយទាំងឡាយ មានសាលាសម្រាប់បណ្ដុះវិជ្ជាជាដើមឲ្យច្រើនទេ ហើយដេកសង្ឃឹមថា "ណ្ហើយចុះ អញចាំមើលព្រេងសំណាង បុណ្យរបស់ចងខ្លួនចុះ បើសំណាងមាន មិនបាច់ប្រឹងរៀនសូត្រឬធ្វើការងារអ្វីក៏នានទេ គង់តែវិជ្ជាទីងទ្រព្យសព្វយ៉ាងកើតឯងមិនខាន" សា.បទ៍ណា ដែនណា ដែលមានគំនិតបែបនេះ មុខជាទឹងធ្លាក់ខ្លួនទៅជាគំនិតទាសៈមិនខាន ។

ប្រទេសណាដែលមិនខំប្រឹងកសាងសាលា រៀនក្បួនខ្នាតទឹងគ្រឿងឧបករណ៍ផ្សេងៗទេ ប្រទេសនោះរមែងគ្មានការចេះដឹង បើគ្មានការចេះដឹងហើយ ធ្វើម្ដេចនឹងឲ្យប្រទេសជាតិមាតុភូមិនោះៗ អង់អាច

ក្លាហានក្នុងចំណោមអ្នកប្រាជ្ញ ដែលមកពីប្រទេសនានាបាន? លុះត្រាតែចំរើនបង្កើតបង្កើនសាងសង់សាលារៀនក្បួនខ្នាតសព្វ ៗ វិជ្ជា ទើបសប្បាយទាំង ៤ ប្រការនោះ ស្ទុះទៅកាន់អារ្យធម៌និងវប្បធម៌ បានពេញបរិបូណ៌ មានទាំងពន្លកឲ្យមែកខ្នែងបញ្ចេញផលាផលឲ្យដល់កុមារកុមារី ដែលកើតខាងក្រោយដោយសួស្ដីបាន, នេះឈ្មោះថាតាក់តែងក្នុងផ្លូវលោក ។

ក្នុងប្រទេសជាតិមួយៗ លុះតែមានទាំងផ្លូវលោកនិងផ្លូវធម៌ ចំរើនកុះករស្មើភាគគ្នាសព្វៗកាល ទើបបានសេចក្ដីសុខសួស្ដី ថ្កុំថ្កើងរុងរឿងជានិច្ចបាន, បើមានតែផ្លូវលោកមួយចំណែក មិនមានផ្លូវធម៌ផងទេ លោកនឹងឆេះឡើងជាភ្លើង ដោយហេតុសត្វនិករមាន រាគៈ ទោសៈ មោហៈ ខ្លាំងប្រណាំងប្រជែងប្រឆាំងឈ្នានីសប្រកួតប្រកាន់ ដំឡើងឫទ្ធិអំណាចពលតែខ្លួន ឥតគិតក្រែងរអែងដល់បុណ្យបាបសោះឡើយ ។ បើមានតែផ្លូវធម៌មួយចំណែក មិនមានផ្លូវលោកផងទេ លោកនឹងក្លាយទៅជាព្រៃ ដោយមនុស្សមិនចំរើនយកចិត្តទុកដាក់ នឹងការរៀបចំស្រុកទេសសោះ ។ ហេតុនេះបានជាព្រះរាជាទាំងឡាយទ្រង់ធ្វើរាជកិច្ចទំនុកបម្រុងផ្គងផ្ដើមទាំងផ្លូវលោកនិងផ្លូវធម៌ ឲ្យចំរើនស្មើភាគគ្នាជាលំដាប់ ដើម្បីឲ្យបានសុខសួស្ដីដល់មហាជន ក្នុងព្រះរាជអាណាចក្ររបស់ព្រះអង្គ ។

ព្រះបរមគ្រូរបស់យើង ពេលដែលព្រះអង្គត្រាស់ដឹងហើយ ទ្រង់ប្រតិស្ឋានសាសនាទុកក្នុងបច្ចុប្បន្ននេះ ដែលសម្រេចដោយប្រយោជន៍ទាំងពីរ ឬប្រភេទធម៌ទាំងពីរនោះ ក៏មានសេចក្ដីរមេបុះក្នុងផ្លូវលោកនិងផ្លូវធម៌ប៉ុណ្ណោះ ដើម្បីឲ្យបានសេចក្ដីសុខ ចំរើនដល់ពុទ្ធបរិស័ទ ក្នុងពុទ្ធសាសនមណ្ឌល ។

ព្រោះហេតុនេះ សាធុជនពុទ្ធបរិស័ទ អ្នកកាន់ព្រះពុទ្ធសាសនា គួរខ្វះស្វាហ៍ស្វែងរកសេចក្ដីចំរើនទាំងផ្លូវលោកនិងផ្លូវធម៌ កុំបីអាក់ខានខាងណាមួយឡើយ ទើបសមតាមពុទ្ធោវាទ ។

ធម្មទេសនាសន្ទនាគថាចប់ត្រឹមប៉ុណ្ណោះ

ធម្មទេសនានុភាវេន និទុក្ខា ហោន្តុ សព្វទា

ដោយអានុភាពនៃធម្មទេសនានេះ សូមពុទ្ធបរិស័ទទាំងឡាយ កុំបីមានទុក្ខសព្វៗកាល ។

ចប់

# រឿងកុណ្ឌលកេសីថេរី

ពាក្យកាព្យ

## ព្រះមហាសុខុមាលី-សេន ឥន្ទប្បញ្ញោ

អាចារ្យសាលាបាលីរង់វត្តផ្ទៅរកា ខែត្រឃ្លាំង (កម្ពុជាក្រោម,

រៀបរៀង

(ត-បប់)

---

## ប្ដូរវគ្គ

## បទភុជង្គលីលា

ប្រែបទភុជង្គលីលា អាបោរម្មា តែងកាយឃ្លាតខ្វី
ស្រែបប្រាប់ធីតាសេដ្ឋី ថាបូរអូនស្រី តែងតួឲ្យខង់ ៗ
ធីតាកល្យាណតែងអង្គ មាសពេជ្របញ្ចង់ ទម្រង់មណីរត្ន
ទំហូរពៃទូរ្យមរកត កណ្ដាលផ្ទៃរត្ន និលរត្នមុក្តា ៗ
កងកកងកនហត្ថា ចិញ្ចៀនរចនា ក្បូរក្បាច់ក្ដីសាយ
សង្វារយ៉ាតេតធាយ ប្រដាប់តែងកាយ ស្រែបបាប់បេញបរ ៗ
ញាតិកាបរិវារឈូធរ សឹងមានអំណរ បើកបរពាជី
សំដៅព្រៃពនាលី ផុតកាលទូរទី ទាល់ទៀបបព្វតា ៗ
លុះដល់ដើងក្ដុំហើយណា សេដ្ឋីធីតា រីងរិតសប្បាយ
ជំនោរពាយោផាត់ផាយ រុក្ខាទាំងឡាយ ផ្លែផ្កាយោនយាន ៗ

សុគន្ធហាក់នន្ទន៍ឧទ្យាន  បុប្ផាផលមាន  រីករុះស្គុសស្គាយ
កុមរិន្ទស្រង់ក្លិនពពាយ  កេសររុះរាយ  ល្ហួយល្ហប់សព្វស្ថាន ។
ធីតាកន្យាថ្កើងថ្កាន  សប្បាយហាក់បាន  បិតហានស្ងួតស្រី
មើលសព្វព្រឹក្សាបក្សី  ខិតជិតស្វាមី  សំណេះបរបា ។
បងអើយនេះហើយចម្ប៉ា  ចម្បីក្តាំងងា  ក្រឹស្នាចន្ទ
លលកលោតលេងទាំងគូ  ចាបពូកហូពូ  ហើរពាសព្រឹក្សា ។
អ្នកបងនុះហោងសារិកា  ចោះចិកផលា  សិតាខ្ទរណាំង
បងអើយនុះហើយក្រសាំង  ក្រសារសំកាំង  សំកុលកន្ទុយ ។
អ្នកប្រុសមើលចុះហ្នុគុយ  ហ្នគូកហើរព្រុយ  ហើរត្រោតពត់កាយ
អ្នកបងនុះហោងពពាយ  ពះពេចប្រញាយ  ប្រញាប់ទំផ្កាស ។
អ្នកប្រុសមើលហ្នុសត្វទាស  សត្វទៀវទំព្រាស  ផ្លេះដើមដែប់ដែក
ចោរប្តីស្បែតខ្ចីចើយរក  ប្រែប្រាប់ថាមក  ប្រញាប់ទឹងទៅ ។
ឲ្យគេវិលទៅលំនៅ  ពីរនាក់យើងទៅ  បូជាទេពតា
ហំកាន់អីវ៉ាន់នេះណា  ប្រដាប់បូជា  កណ្តៀតទៅផង ។
ធីតាយាត្រៃញ៉ែងញ៉ង  ពោលថាអ្នកបង  អញ្ជើញដើរមុខ
ចោរនាំនាងដើរតក្រុក  កាត់រាបវន៍រុក្ខ  តក្រុកទៀងភ្នំ ។
លុះដល់កណ្តាលផ្លាធំ  ថ្ងៃសប់ដុំ ៗ  ទៀបជ្រោះបបាត[1]

---

១ មើលថា ប៉ះ ប៉ាត ។

ទឹកជ្រោះជ្រៅជ្រះថ្លាស្អាត  ទីនោះគ្មានជាតិ  ត្រីចកឈើស្មៅ ។
មានតែថ្មស្រួចៗនៅ  មនុស្សសត្វធ្លាក់ទៅ  មុតដូចសស្ត្រា
ដូចកាត់ដូចកាប់ហ្នោះណា  ខ្ទេចខ្ទីកាយា  បីប្អូនកំណត់ ។
គេហៅហោរៈបបាត  ព្រោះតែងពិឃាត  ហោរនាទីនោះ
ជីតាកន្សាញ៉ោះញ៉ោះ  ដើរដល់ទីនោះ  នាងសួរប្តីថា: ។
"ដល់ហើយអ្នកអើយទីណា  នឹងរៀបបូជា  អញ្ជើញតាមចិត្ត"
អាហោរមោហៈទុច្ចរិត  ស្តាប់ស្តីមិនស្និត  មិនខ្ចីឆ្លើយឆ្លង ។
ជីតាសួរថាអ្នកបង  ហេតុអ្វីប្អេះហោង  អ្នកស្ងៀមព្រងើយ
ប្តីមួយខ្វះអ្វីទៅឡើយ  ទៀនធូបមានហើយ  បូជាត្រង់ណា? ។
ហោរប្រាប់ថាគ្រឿងបណ្ណា-  ការនេះទេត្តា  មិនត្រូវការទេ
អញត្រូវការកាប់តែមេ  ម៉េចដឹងប្តូទេ  វិលវិញមិនបាន ។
ប្រដាប់សម្លាប់តែងប្រាណ  មាសពេជ្រប៉ុន្មាន  បានអញលក់ចាយ
ជីតាកន្សាឆើតឆាយ  បានស្តាប់បរិយាយ  ហោរប្រាប់ដូច្នោះ ។
តក់ស្លុតរន្ធត់ញ័រពោះ  មិនដឹងពិគ្រោះ  គិតកែយ៉ាងណា
ទើបសួរទាំងភិតភ័យថា  នាងខ្ញុំនេះណា  មានទោសដូចម្តេច? ។
ក្រែងគ្រឿងរបស់មាសពេជ្រ  ខ្លួនខ្ញុំនេះស្រេច  សម្រាប់អ្នកហើយ
នឹងកាប់សម្លាប់ថ្វីឡើយ  ទុកនៅអ្នកអើយ  គ្រាន់បំរើអ្នក ។
គ្រាមានទុក្ខព្រួយធុរ:  ខ្លួនខ្ញុំនេះជាក់  ជាអ្នកបំរើ

គ្រប់កិច្ចគ្រប់ការសារពើ សម្រាប់ខ្ញុំតើ មានប្រយោជន៍អ្វី? ។
សូមអ្នកមេត្តាប្រណី ទុកជាទាសី បំរើតទៅ
ចោរថាបើទុកហងនៅ ហើយហងនឹងទៅ ប្រាប់ម្ដាយឪពុក ។
មុខជាចាប់អញដាក់គុក អញនឹងមិនទុក ហងឲ្យអំពល់
ជឿចុះទៀងស្លាប់កុំឆ្ងល់ កុំសោកសល់វល់ អំពល់ខ្លាំងពេក ។
ទុកជាហងទួញយំយែក ឈាមចេញពីភ្នែក មិនបានរស់ឡើយ
សេដ្ឋីតាត្រាណត្រើយ ស្ដាប់ពាក្យចោរហើយ រងរិតតក្កមា ។
ទើបគិតថារីប្រាជ្ញា គ្មានអ្នកឯណា ទុកឆាដាំស្ល
គ្រាមានអាសន្នមន្ត្រក គេតែងគេយក៍ ប្រាជ្ញាមកគិត ។
ឥឡូវត្រូវសូន្យជីវិត មានតែអញគិត ប្រើប្រាជ្ញាម្ដង
គិតហើយឆ្លើយថាអ្នកបង នាងខ្ញុំនេះហោង មុខជានឹងស្លាប់ ។
សូមអ្នកអនុញ្ញាតឲ្យក្រាប សំពះលាបាប លាទោសនឹងអ្នក
ក្រែងមានប្រមាថពាធពាក្យ ពុំគួរនឹងអ្នក ម្ដេចៗ ពីមុន ។
សូមអ្នករំឭកដល់គុណ ដល់កាលពីមុន ខ្ញុំឲ្យលោះអ្នក
មកនៅសន្និកសរមែក រួមរូបនឹងអ្នក ជាប្ដីប្រពន្ធ ។
ឥឡូវខ្ញុំត្រូវសូន្យជន្ម សូន្យជីពជីវ័ន ជីវិតមរណា . . .
អាចោរមោហោពាលា ពាលលុះលោភា លោភៈមោហន្ធ ។
អង្គុយចុះឲ្យប្រពន្ធ គោរពអភិវន្ទ ភ្លើភ្លេចអាត្មា

នារីសោកីព្រាជ្ញ ប្រទក្សិណអា- ហោររូបវន្ទា ។
ទូញសោកអាមោ៉កមហិមា: "បងអើយអូនលា បងទីបំផុត . . .
ក្រញូក្រាបហាក់ដាបស្រំយុត ដង្គង់លង់លុត លំអុតវន្ទា ។
អាហោរឆ្វេឆ្វេសអង្គា ដោយនាងពុំងា ឧបរិតពីក្រោយ
អន្ទែលធ្លាមកបណ្ដោយ ដៃផ្កើះគូថក្រោយ បណ្ដោយប្រានបោះ ។
ទម្លាក់ហោរចុះក្នុងជ្រោះ ហោរធ្លាក់ទៅនោះ ទង្គិចសិលា
តួប ៗ មុតដូចសស្ដា ខ្ទេចខ្ទីកាយា រអោបរអិត ។
ក្សិណក្ស័យប្រល័យជីវិត ព្រោះផលទុច្ចរិត របស់អាត្មា
គ្រានោះអស់ពួកទេព្ដា ដែលនៅរក្សា គិរីបពិត ។
ឃើញហោរនឹងនារីរត្ន សុទ្ធសឹងលាន់មាត់ សរសើរនាងថា:
"ធម្មតាឯព្រាជ្ញ ប្រសើរថ្លៃថ្លា ប្រពៃស្រួចស្រស់ ។
មិនមែនមានតែបុរស ស្រីៗ ទាំងអស់ គង់មានដែរណា
មើលហ្ន៎សេដ្ឋីធីតា នាងប្រើប្រាជ្ញ សម្លាប់ហោរបាន ។
ប្រាជ្ញនេះមហាចំណាន ដោះទុក្ខភ័យបាន ក្សេមក្សាន្តសុខា
អ្នកប្រាជ្ញតែងសរសើរថា រស់ដោយប្រាជ្ញ ប្រសើរក្រៃលែង ។
ការបានប្រាជ្ញនេះឯង ប្រសើរលើសលែង លើសលើអ្វីៗ
ហេតុនេះនរៈប្រុសស្រី អ្នកកុំគប្បី មើលងាយប្រាជ្ញ ។
គួរខិតគួរខំឧស្សាហ៍ រិះរកប្រាជ្ញ មកបរិហារប្រាណ
នឹងបានសុខសមក្សេមក្សាន្ត យសសក្ដិចំរើនថ្កាន ប្រពៃពេកអើយ ។

# បទព្រហ្មគីត

ប្រែបទព្រហ្មគីតកាល　　នឹងដំណាលចរចាចែង
ពីនាងនាថកណ្ដែង　　នាកណ្ដាលបព្វតា
ពពកពពូនពាប់　　ហាក់ដូចជាប់ចុងព្រឹក្សា
មេឃមីរដេរដាសដា　　ខ្យល់ផាត់ផាយធ្លាយលើសលន់ ។
នាងសែនសោយសោកសព្វ　　សល់សែនថប់ៗពេកពន់
មិនដឹងបើនឹងគន់　　គន់គិតទៅតាមផ្លូវណា
ភិតភ័យញ័របំប្រប់　　ស្ញើរសន្ធប់សូន្យដីក៏
តែអង្គឯងឯកា　　គ្មានអ្នកណានៅជាគ្នា ។
មើលព្រៃស្ងាត់ជ្រងំ　　គន់មើលភ្នំធំមហិមា
គន់មើលទីនានា　　នាង់តុំងាវែវជាទុក្ខ
គិតសព្វវេងថប់ថា　　“អញនេះណាៗ មាសមុខ
ប្រសិនវិលទៅស្រុក　　សមទុក្ខពុកម្ដាយផ្ដាសា ។
ថាអញនេះអប្រិយ　　ឲ្យលោះប្ដីមកស្នេហា
ស្នេហ៍ហើយនឿយចិន្ដា　　ប្រហារៈចោលៈដោយចិត្តក្លែង
បើទុកជាអញប្រាប់　　ថាចោរចាប់ៗ កំហែង
សម្លាប់អង្គអញឯង　　ព្រោះចង់បានអាភរណា ” ។

នរណាទឹងជឿឡើយ　　ពុំខ្លាអើយកម្មអាត្មា
ចេះអញទឹងយាត្រា　　តាមយថាកម្មអញឯង
គិតហើយដោះសង្វា　　អាករណាត្រៀងតាក់តែង
ហោលនៅទីនោះឯង　　ទាំងអស់ហើយទើបយាត្រា ។
ញ៉ូវញោបចំប្រែបអង្គ　　ទន់ជន្គង់ជង់បន្ទា
ជំពប់ជុំថ្មា　　ទប់អាត្មាស្ទើរមិនបាន
ចុះចាកកំពូលភ្នំ　　ព្រៃទុរគមរហោស្ថាន
ខ្ទាបចិត្តអាណិតប្រាណ　　ព្រោះមកបានទុក្ខវេទនា ។
គិតឃើញកាលស្រណុក　　ស៊ីសោយសុខក្នុងគ្រឹហា
ឪពុកម្តាយម៉ែងមា　　មូលមិត្តគ្នាជាសុខា
ចិត្តចង់ស្រើបស្រាលត្រេក　　ឃ្លានខ្ទាំងពេកពកតណ្ហា
មិនជឿស្តាប់មាតា　　បិតាផងខ្លួនប្រដៅ ។
ឪពុកម្តាយចង់បាន　　ឲ្យសុខសាន្តដល់កូនចៅ
ឲ្យថ្កុំថ្កើងពង្សដៅ　　មិនឲ្យសៅសោយសោកា
ខ្លួនរឹងចចេសចង់　　តាមចំណង់ផងអាត្មា
ព្រោះយល់ថាតណ្ហា　　នាំកាយាឲ្យស្រួលពិត ។
មិនមែនទេទេពតា　　កុំយល់ថាការស្នេហ៍ស្និទ្ធ
ទឹងមនុស្សពាលទុច្ចរិត　　នាំជីវិតឲ្យស្រួលឡើយ

អ្នកអើយនាងស្រីៗ គួររើសប្ដីណានាងអើយ
ខ្លួនខ្ញុំខុសផ្រុលហើយ កាលណាឡើយបានសុខា ៗ
ដូច្នេះនាងនៅក្រោយ គួរបណ្ដោយតាមមេបា
ឲ្យរើសតូជពង្សា រើសចរិយាសីមេត្រី
រីខ្លួនខ្ញុំនេះណា ស្រើបស្នេហាចង់បេតី
ទឹងទោរសោអប្រិយ យកស្វាមីមនុស្សទុច្ចរិត ៗ
បាបកម្មតាមមកផ្ដ- ន្ទាទាន់ហាន់ដល់ដូចចិត្ត
កំណាចព្រោះគំនិត ត្រិះត្រឹមត្រេកត្រង់ត្រអាល
ចចេសចើកចោរចង់ តាមចំណង់ឃ្លានស្រើបស្រាល
អកុសលផ្ដល់បណ្ដាល កមផ្លាញ់ផ្លាលឲ្យខ្លោចផ្សា ៗ
អស់អ្នកនាងនៅក្រោយ កុំបណ្ដោយតាមតណ្ហា
ទុកជាស្រើបយ៉ាងណា ខំរក្សាខ្លួនឲ្យបាន
នាងអើយការស្រើបស្រាល កាមបណ្ដាលគ្មានសុខសាន្ត
នាំឲ្យអាស្រូវប្រាណ បានវេទនាដូចជាខ្ញុំ ៗ
គួរស្ដាយរូបអាត្មា ស្ដាយចរិយានាងក្រមុំ
កុំស្រើបស្រាលដូចខ្ញុំ គួរតែកុំប្រសើរជាង
គួរនៀយណាយអាម៉ាស គួរតែខ្មាសគួរណាស់ពង
គួរគេចគួរចៀសពង រក្សារូបឲ្យសុខអើយ ! ៗ

# បព្វជ្ជាវគ្គ

## បទកាកគតិ

ប្រែបទកាកា ដំណាលចរចា ចាប់តែងសេចក្តី ថាថ្លែងអំពី នារីប្រិមប្រិយ ខំប្រឹងឃ្លាតខ្លី ពុះបាកបព្វតា ៗ លន្ទង់លន្ទោច ត្រមង់ត្រមោច កណ្តាលព្រឹក្សា តេជះកុសល ជួយផ្តល់ធីតា ឲ្យ ខំយាត្រា តាមវាសនានាង ៗ សត្វពាឡម្រឹគា សិង្ហសីហ៍នានា ខ្លាខ្លាចចៀសវាង គោព្រៃក្របី ភិតភ័យទីងនាង បរវៀសចៀសវាង មិនអាចយាយី ៗ នាងដើរលុះដល់ ទើបពះយង់យល់ អាភមជាទី បរិព្វាជកៈ ទីងបរិព្វាជី នោះក៏នារី ចូលទៅវន្ទា ៗ ក្រាបថ្វាយបង្គំ លោកគ្រូជាធំ សូមសុំបព្វជ្ជា សូមមានមេត្តា ករុណាកំព្រា មកសូម បព្វជ្ជា ទីងព្រះគុណម្ចាស់ ៗ បរិព្វាជកា បានស្តាប់ធីតា គាប់ចិន្តា ណាស់ ប្រជុំគ្នាគ្នី មកមីរដេរដាស ជួបជុំរហ័ស បំបួសធីតា ៗ ទើបឲ្យនាមោ ហៅថា "ជម្ពូ បរិព្វាជិកា" ព្រោះនាងបួសរួច រៀន ក្លួចប្រស្នា ជម្ពូហត្ថា ជៈអាចសេចក្តី ៗ គ្របង្គាប់ថា ចូរនាងយាត្រា ទៅសព្វបុរី ស្រុកតូចស្រុកធំ និគមណាក្តី ប្រយោជន៍ដើម្បី សាកសួរបញ្ហា ៗ បើមានគ្រហស្ត ជាតិជាបុរស អាចដោះប្រស្នា បានរួចរួសរាន់ មួយពាន់ប្រការ នោះចូរធីតា ស្នេហាមេត្រី ៗ ឧស្សាហ៍សង្វាត គោរពទៀបបាទ សព្វពេលប្រក្រតី ព្រោះគេជាតិ ប្រាជ្ញ តែងអាចដោះស្តី គួរតែពិសី មេត្រីជាគ្នា ៗ បើបព្វជិតណា

អាចដោះបញ្ហា មួយពាន់កាថា ឆ្លើយរួចទាំងអស់ គ្មានខុសមួយឃ្លា នោះបូរពំងា បួសរៀនតាមចុះ ៗ តាំព្រោះបព្វជិត នោះជាបណ្ឌិត វិសិដ្ឋប្រាជ្ញប្រុះ កបដោយញាណញេយ្យ ប្រពៃឆ្ងៀវឆ្ងុះ អាចដឹង សព្វសុះ អស់អាថ៌ប្រស្នា ៗ នាងបរិញ្ញាជី បានស្ដាប់ពាទី គ្រូប្រាប់ ចេះណា លើកហត្ថបង្គំ ដាក់ផ្គុំកេសា រួចរៀបអាត្មា ស្រេចបាច់ ចរលី ៗ នាងដើរបិណ្ឌបាត ខិតខំសង្ឃាត សួរសាកពាទី សព្វស្រុក ខេត្តឃុំ និគមធានី ដើរសួរសព្វទី រាជគ្រឹះបុរី ៗ សាកសួរលុះដល់ ដែនដីកោសល ក្រុងសាវត្ថី ពុំមានអ្នកប្រាជ្ញ ដែលអាចដោះស្ដី ប្រស្នាបាលី នៃនាងបានឡើយ ៗ មួយថ្ងៃនោះណា បរិញ្ញាជិកា រៀបខ្លួនស្រេចហើយ យកមែកព្រីងថ្មី ពូនដីរួចហើយ ជីតាត្រាណ ត្រើយ អធិដ្ឋានថា ៗ អ្នកណាអាចហ៊ាន ជាន់ដកបំពាន់ មែកព្រីង នេះណា អ្នកនោះត្រូវឆ្លើយ បើកដើយប្រស្នា នឹងខ្ញុំនេះណា ទើបរួច ខ្លួនបាន ៗ ក្រោយនាងចេញទៅ មានពួកក្មេងនៅ ប្រជុំនាស្ថាន ទីនោះខ្សៀវខ្សា តែថាមិនបាន បៀតបៀនដល់ស្ថាន ជម្ពូសាខា ៗ អាខ្លះធ្វើហ៊ាន សុះទៅបំពាន ដៃប្រឹងប្រវ៉ា ខ្លះរត់ខ្លះឈរ ខ្លះលបាប់ ស្នា ខ្លះស្រែកថាអា លាញរើយប្រយ័ត្ន ៗ ខ្លះហ៊ានចូលជិត ខ្លះ ខ្លាចភ័យគិត សម្ងំស្ងៀមស្ងាត់ ខ្លះលោតប្រឡែង ខ្លះរ៉ែងគូចប៉ាត់ ខ្លះរត់ប៉ាត់ញ៉ាត់ ដេញគ្នាប្រញាយ ៗ ជួនថ្ងៃនោះណា អគ្គសាវិកា

សារីបុត្រប្រាជ្ញប្រាយ ដល់ទីនោះឯង ឃើញក្មេងទាំងឡាយ ខ្សៀវ
ខ្វាសប្បាយ ទើបសួរទៅថា: ៗ នែហើយពួកក្មេង អស់ឯងនេះលេង
អីនេះអ្វីអា មែកព្រីងផ្គុកខ្សាប់ សំបាច់នរណា ថ្វីក៏ពួកអា មិនហ៊ាន
ទៅជិត ៗ ពួកក្មេងទូលថា ពួកខ្ញុំករុណា នេះខ្លាចភ័យភិត នាង
បរិព្វាជី នារីបព្វជិត ដេញដោលឲ្យគិត រកអាថ៌ប្រស្នា ៗ – បើយ៉ាង
នេះពិត ពួកឯងកុំភិត ភ័យខ្លាចឡើយណា កំទេចឲ្យអស់ ការដោះ
ប្រស្នា ស្រេចលើអាត្មា ជានាឆ្លើយជូន ៗ ពួកក្មេងបានប្បាប់
រត់ទៅប្រញាប់ កញ្ជ្រៀវអឹងកង ខ្លះដាន់ខ្លះកាច់ ខ្លះបាចខ្សាច់ផង
ទ្រហឹងអឹងកង កញ្ជ្រៀវស្រៀវស្រែក ៗ កំពុងតែដាន់ នារីមកទាន់
ប្រពូនបែកខ្ញែក ខ្លះរត់ទៅឆ្ងាយ ខ្លះប្រាយដោយឡែក នារីក៏ស្រែក
គំរាមទៅថា: ៗ លោកហើយម្តងនេះ បានពួកឯងបេះ ឆ្លើយអាថ៌
ប្រស្នា ចូរប្រមូលគ្នា កុំអាទៅណា អញសួរសិនហ៍ បំណាច់ក្លា-
ហាន ៗ ពួកក្មេងឆ្លើយថា លោកគ្រូទុះណា លោកដោះសាបាន
អញ្ចឹងសួរចុះ ចំរុះប៉ុន្មាន ពួកយើងគ្រប់ប្រាណ សឹងបានលោក
ប្រើ ៗ នាងបរិព្វាជី ចូលជិតវត្តី បង្គំទូលស្មើ ថាព្រះគុណម្ចាស់
បានត្រាស់ចាត់ប្រើ ឲ្យពួកក្មេងរើ មែកព្រីងប្តូរអ្វី? ៗ អាម:កគិទី
អើបរិព្វាជី ចុះមានការណ៍អី ពួថាព្រីងព្រឹង ហើយនឹងផ្គុកដី នោះ
ជាបាលី កើតអាថ៌ប្រស្នា? ៗ- ទានប្រោសពិតណាស់ ត្រូវព្រះគុណម្ចាស់

ទទួលដោះសា រាទៈនៃធាន់ មួយពាន់បញ្ហា តើព្រះករុណា ទទួល·ឬមេ៉ច? ។- អាមៈភគិទ អើបរិញ្ញាជី អាត្មាមិនគេច រសៀលនេះណា ធីតាកុំភ្លេច ចង់សួរដូចម្តេច ទៅវត្តអាត្មា ។- ទានប្រោសគាប់ណាស់ រសៀលខ្ញុំម្ចាស់ រូតរះយាត្រា ចេះសូមព្រះគុណ និមន្តចុះណក រសៀលស្សូរ្យា ខ្ញុំទៅវិហារ ។

## បញ្ហាវគ្គ

## ព្រហ្មគីត

លុងលុះចូលសាយណ្ហ ទាបទោរទន់ព្រះសូរ្យា
សូរ្យសែងលែងក្តៀវក្លា អ័ព្ទស្រទន់ស្រទំចុះ
បញ្ចាំងពណ៌សុវ័ណ្ណ ហាក់ដូចស្ពានកញ្ចក់ឆ្លុះ
ភ្លឺផ្ទុកពព្រោតព្រុះ ជាប់ចុងចុះឈើនានា ។
រាយោគ៍ផាត់ផាយ សុសសព្ទសាយផែនពសុធា
ឲ្យបានដឹងថាជា ចូលវេលារសៀលហើយ
នាងបរិញ្ញាជិកា រៀបអត្តាពុំលង់ឡើយ
លុះរៀបស្រេចបាច់ហើយ ក៏ចេញចរចូលជេតពន ។
មិច្ឆាទិដ្ឋិកា នឹងសម្មាទិដ្ឋិជន
ដើរតាមចាំគយគន់ ចូលជេតពនស្តាប់បញ្ហា
មិច្ឆាទិដ្ឋិជន រិះគិតគន់ថាប្រស្នា

នាងបរិព្វាជិកា សួរមហាសារីបុត្ត ។
ដល់មួយពាន់បញ្ហា មានអត្ថាជ្រៅបំផុត
មុខតែសារីបុត្ត ជាប់ពិរុទ្ធខ្វះមិនខាន
សម្មាទិដ្ឋិកា រិះគិតថាយើងនឹងបាន
ស្តាប់ធម៌យ៉ាងចំណាន ប្រាជ្ញពីរប្រាណចោទឆ្លើយគ្នា ។
នាងបរិព្វាជិកា ដល់ហើយណាឧនវន្ទា
អង្គុយសន្ទនា សារណីយកថា
រួចលើកយកគាថា មកតាំងជាអាថិប្រស្នា
ជាមួយពាន់បញ្ហា នាងបុប្ផាឥតបន្ទោះ ។
ព្រះសារីបុត្តប្រាជ្ញប្រាយ ឆ្លើយដោះស្រាយឥតសល់សោះ
ឆ្លើយសព្វឥតបន្ទោះ លុះចប់អស់មួយពាន់ឃ្លា
ទើបសួរថាបញ្ហា ដែលអាត្មាវិសជ្ជនា
មកនេះច្រើនមហិមា មួយពាន់ឃ្លាណានាងអើយ ។
ឥឡូវត្រូវអាត្មា ភាពបុប្ផានាងវិញហើយ
តើនាងទទួលឆ្លើយ ផងអាត្មាឬទេអេះ?
— បានប្រោសខ្ញុំករុណា សូមសន្យាថាបើបេះ
នឹងឆ្លើយតាមចំណោះ បើមិនចេះសួរវិញទេ ។
— ធម្មជាតមួយគឺអ្វី? ចូរពិសីគិតរិះរេ

– នាងគិតមិនយល់ទេ    មិនដឹងត្រូវធ្វើយ៉ាងណា
ទើបទូលតបថាខ្ញុំ    រិះរកពុំយល់ប្រស្នា
នេះទេសូមមេត្តា    ធម៌ឯកានុ៎ះគឺអ្វី? ។
– ធម្មជាតិនោះសោភ័ណ    គឺពុទ្ធមន្តណាពិសី
បើពោលរួមឲ្យខ្លី    បានសេចក្តីថានិព្វាន,
– ទានប្រោសពីពេះផ្ទៃក    នេះបំឡែកកម្រមាន
សូមប្រោសប្រាប់ឲ្យទាន    ធម៌និព្វានដល់ករុណា ។
– ការរៀនពុទ្ធមន្តនោះ    លុះតែបួសបែបអាត្មា
ទើបលោកឲ្យសិក្សា    អត្ថគាថាពុទ្ធបាលី,
នាងបរិព្វាជិកា    បួសបានជាព្រះថេរី
នាមកុណ្ឌលកេសី    ប្រឹងឃ្មាតខ្មីខំសិក្សា ។
មិនជាយូរប៉ុន្មាន    សម្រេចបានអរហត្តា
ជាមហាសាវិកា    ក្នុងសាសនាព្រះគោតម;
រឿងរ៉ាវនេះឯង    ខ្ញុំចាត់ចែងពីដើមចម
តាមបែបតាមដោយគ-    ម្ពីរបាលីព្រះធម្មបទ ។
សង្ខេបបែបវោហារ    ពុំពិស្តារបានមត់ចត់
ប៉ុណ្ណោះស្មោះសន្ទត់    ថាចប់ចុះអស់ឯវំ ។

ចប់

ព្រះមហាឧត្តមវិជ្ជា ផលញ្ញាណោ ប៊ុង-ប៉ម
អាចារ្យសាលាបាលីរង វត្តបទុមវតី ក្រុងភ្នំពេញ រៀបរៀង
ឃុនបណ្ណានុរក្ស ប៊ូ-ប៉ូ នៅពុទ្ធសាសនបណ្ឌិត្យ អ្នកពិនិត្យ

(តមក)

---

## ឧបាយបណ្តុះនិស្ស័យទី ៥

## និស្ស័យស្រឡាញ់ភក្តី (ស្វាមីភក្តិ)

ការស្រឡាញ់ភក្តីគឺអ្វី? ការស្រឡាញ់ដោយទឹកចិត្តពប់អានយ៉ាងបរិសុទ្ធពិតៗ ឈ្មោះថាស្រឡាញ់ ។ ការគោរពសមល្មម ទាំង ជឿ ដោយទឹកចិត្តសុចរិតស្មោះត្រង់មិនគិតវៀចវេរទុយស ឈ្មោះថា ភក្តី ។ បើលោក-អ្នកជ្រាបសេចក្តីត្រឹមប៉ុណ្ណោះហើយ ក៏តបបញ្ហានេះបានភ្លាមថា: សេចក្តីស្រឡាញ់ក្នុងវត្ថុ ឬ បុគ្គល ដោយទឹកចិត្តពប់អានយ៉ាងបរិសុទ្ធពិត ៗ ទាំងការគោរពសមល្មមជឿស្តាប់ក្នុងវត្ថុ ឬ បុគ្គល ដោយទឹកចិត្តសុចរិតស្មោះត្រង់ មិនគិតវៀចវេរទុរយស បង្អោនខ្លួនដើម្បីជាប្រយោជន៍ដល់វត្ថុ ឬ បុគ្គលដែលខ្លួនគោរពស្រឡាញ់នោះពិត ៗ នេះឯងចាត់ថា "សេចក្តីស្រឡាញ់ភក្តី" ។

មនុស្សដែលមាននិស្ស័យស្រឡាញ់ភក្តី រមែងធ្វើទាំងនិយាយដោយចិត្តសុចរិត គោរពស្រឡាញ់ចំពោះវត្ថុ ឬ បុគ្គលដទៃ ដូចជាគោរព

ស្រឡាញ់ចំពោះខ្លួនឯង មានសេចក្ដីព្រមព្រៀងគ្នារវាងគ្រួសារញាតិមិត្របងប្អូន សុចរិតស្មោះត្រង់ចំពោះមិត្តភក្តិរួមជាតិ ។ អ្នកដែលមាននិស្ស័យស្រឡាញ់ភក្តិនេះបើជាបុត្រធីតាក៏ស្រឡាញ់ភក្ដីចំពោះមាតាបិតា, បើជាសិស្ស ក៏ស្រឡាញ់ភក្ដីចំពោះគ្រូអាចារ្យ, បើជាអ្នកតូច ក៏ស្រឡាញ់ភក្ដីចំពោះអ្នកធំ, បើជាពលរដ្ឋ ក៏ស្រឡាញ់គោរពប្រមុខរបស់ខ្លួន មើលឃើញទុកដូចដែលព្រឹទ្ធាចារ្យប្រៀនប្រដៅ ដូចជាឃើញកំណប់ទ្រព្យដ៏ប្រសើរដែលឋិតនៅចំពោះមុខ និងខ្វល់ខ្វាយអើពើជួយកិច្ចការរបស់ពួកគណៈ ឲ្យឈានទៅកាន់សេចក្ដីចំរើន ។

លោក-អ្នកទាំងឡាយ មាននិស្ស័យនេះហើយឬនៅ? បើមានហើយ និស្ស័យរបស់លោក អ្នក ក៏នឹងបង្ហាញឲ្យឃើញប្រាកដថា ‘‘លោក-អ្នកមានសេចក្ដីស្រឡាញ់ភក្ដីសុចរិតស្មោះត្រង់ ចំពោះវត្ថុ ឬបុគ្គល ដូចជាស្រឡាញ់ភក្ដីខ្លួនឯង មិនគិតវៀចវេរទុយិស មានទឹកចិត្តស្រឡាញ់ភក្ដីពិត ៗ ធ្វើខ្លួនឲ្យជាកំឡាំងក្នុងកិច្ចការសាធារណៈ តាំងចិត្តធ្វើករណីយកិច្ចតាមដែលខ្លួនបានព្រមទទួលមកដោយសុចរិតស្មោះត្រង់ មិនធ្វើតែចំពោះមុខ សូម្បីកំបាំងមុខក៏ធ្វើដូចគ្នា កាលដល់វេលាត្រូវការក៏បង្អោនខ្លួនធ្វើពលីកម្ម ដើម្បីជាប្រយោជន៍ដល់វត្ថុ ឬបុគ្គលដែលខ្លួនគោរពស្រឡាញ់នោះបានពិត ៗ’’ ។

ការស្រឡាញ់ភក្ដី ជាសសរគោលបង្គោលឲ្យយើងមានសន្តិសុខ ១ ផ្នែក ។ សូមលោក-អ្នកពិចារណាក្នុងចំណែកសំខាន់នៃសសរគោលបង្គោល

គឺសេចក្ដីស្រឡាញ់ភក្ដីនោះឱ្យចូលចិត្តជាក់លាក់ដូច្នេះថា មនុស្សយើងទាំងសត្វមានរូប, ជីវិតទាំងចិត្តដូចគ្នា តែការតាំងនៅនៃមនុស្សទាំងសត្វនោះខុសគ្នាឆ្ងាយណាស់ ៗ សត្វក្នុងព្រៃ ក្នុងទឹក បេះតែប្រហារគ្នាទាំងស៊ីគ្នាឯងមិនមានឈប់ឈរ ៗ សូម្បីមនុស្សត្រូវការប្រហារ ឬចាប់វាមកធ្វើជាអាហារកាលណាក៏បាន ៗ សភាពតាំងនៅក្នុងការគ្រប់គ្រងជីវិតរបស់សត្វ រមែងជាភ្លើងនរកដុតបំផ្លាញ ឱ្យក្ដៅក្រហាយយ៉ាងសាហ័ស ៗ

បើលោកអ្នកពិចារណាឱ្យឃើញច្បាស់ដោយជាក់លាក់ហើយ មុខជានឹងដឹងភ្លាមថា សត្វទាំងនោះ មិនមែនមានឋានៈ ដូចជាលទ្ធិខ្លះដែលយល់ឃើញថា ព្រះម្ចាស់សួគ៌សាងវាមកឱ្យជាដូច្នោះ ឬ ព្រោះវាជាសត្វមានសភាពតាំងនៅដូច្នោះឡើយ ៗ តាមសេចក្ដីពិត ដែលវាមានការគ្រប់គ្រងជីវិតជានរកដុតបំផ្លាញគ្រប់វេលានោះ ព្រោះវាខ្វះបង្គោលសំរាប់ការពារ ៗ ចំណែកមនុស្សដែលមានលក្ខណៈផ្សេងគ្នាពីសត្វ ក៏ព្រោះមនុស្សយើងមានសេចក្ដីស្រឡាញ់ភក្ដី ជាបង្គោលសំរាប់ពឹងផ្អែក គឺស្រឡាញ់ភក្ដីចំពោះរបស់ឃុំគ្រង ដែលជារបាំងយ៉ាងសំខាន់ ដើម្បីសន្តិសុខដែលកាលពីដើមធ្លាប់មានតែ ៣ ប្រការ គឺជាតិ, សាសនាទាំងព្រះមហាក្សត្រ; ដល់មកក្នុងគ្រានេះ បន្ថែមរដ្ឋធម្មនុញ្ញមួយមកទៀត ត្រូវជាសេចក្ដីស្រឡាញ់ភក្ដីមាន ៤ ប្រការគឺ:

១ — **ស្រឡាញ់ភក្ដីចំពោះជាតិ** — ប្រជុំជនដែលតាំងនៅជាពួកជាគណៈ មានកំណើតពូជពង្ស ឬ សញ្ជាតិជាប់តមកអំពីផៅពង្សជា

មួយគ្នា មានភាសានិងអក្សរសាស្ត្រជាមួយគ្នា មានភូមិលំនៅទីអាស្រ័យរួមគ្នា គឺនៅក្នុងខេត្តនៃការគ្រប់គ្រងជាមួយគ្នា មានចរិតប្រពៃណី ឬទំនៀមទំលាប់ស្រដៀងគ្នា កាន់សាសនាជាមួយគ្នាដោយច្រើន និងមានប្រមុខជាអ្នកបង្គាប់បញ្ជាកិច្ចការឲ្យប្រព្រឹត្តទៅជាមួយគ្នា ហៅថា ជាតិ ដូចយ៉ាងជាតិកម្ពុជា ក៏គឺអ្នកកម្ពុជាទាំងអស់រួមគ្នា ទាំងដែលមានពូជពង្សសែស្រឡាយជាប់ជាដំណគ្នាមក និយាយភាសាជាមួយគ្នា មានរូបរាងលក្ខណៈនិងទំនៀមប្រពៃណីដូចគ្នា ទាំងដែលមានសញ្ជាតិជាខ្មែរតាមច្បាប់ទំលាប់ផង រួមសេចក្តីមកថា ជាតិខ្មែរកម្ពុជា ក៏គឺជាតិខ្មែរដោយកំណត់ និងដោយសញ្ជាតិរួមគ្នាទាំងអស់ ។

ជាតិ រមែងជាទីអាស្រ័យទ្រទ្រង់ជីវិត និងវង្សត្រកូលនៃពួកជនរបស់ជាតិ ជាទីរួមនៃប្រយោជន៍ចំណែកធំ និងជាទីពឹងដ៏ក្សេមក្សាន្តរបស់ប្រជាជននៃជាតិ ។ មនុស្សគ្រប់រូបនៃជាតិ ត្រូវពឹងពាក់អាស្រ័យគ្នានិងគ្នា ក្នុងការគ្រប់គ្រងជីវិតរួមគ្នា មានទាំងចំណែកបាន ទាំងចំណែកបង់ រួមសុខរួមទុក្ខជាមួយគ្នានិងជាតិ, ជាតិប្រព្រឹត្តទៅយ៉ាងណា ទោះជាសុខក្តី ជាទុក្ខក្តី ចំរើនក្តី វិនាសក្តី មនុស្សក៏ត្រូវតែប្រព្រឹត្តទៅយ៉ាងនោះដែរ ។ សេចក្តីសុខទុក្ខ ចំរើន ឬវិនាសរបស់ជាតិ ធ្លាក់ទៅជារបស់មនុស្សទាំងអស់ ។ មនុស្ស ជាអ្នកមានចំណែកបាន ចំណែកទទួលស្មើគ្នាទូទៅ គឺកាលបើជាតិ បានសុខទុក្ខ ចំរើន ឬវិនាស មនុស្សក៏ត្រូវបានសុខទុក្ខ ចំរើនឬវិនាសផងដែរ ។

ជាតិសំខាន់ជាងមនុស្ស ព្រោះបើជាតិនៅគង់វង់វែងប៉ុនដំហារ មនុស្សរមែងមានសន្តិសុខ និងមានសិទ្ធិ ឥស្សរភាព សេរីភាព សម្បូណ៌ពេញលេញ ។ បើជាតិវិនាសសាបសូន្យទៅហើយ សូម្បីនៅមានសល់មនុស្សខ្លះក៏ដោយ ក៏អ្នកនោះ ឥតមានសន្តិសុខ និងសិទ្ធិ ឥស្សរភាព សេរីភាពដែរ ដូចយ៉ាងជាតិដែលធ្លាក់ទៅជាទាសៈរបស់ជាតិដទៃ ត្រូវជាតិរបស់ជន ដែលជានាយចៅហ្វាយគ្រប់សង្កត់ ដណ្តើមយកប្រយោជន៍ដែលខ្លួនគួរមានគួរបានទៅអស់រលីង មិនយល់ព្រមបណ្តោយឲ្យមានសិទ្ធិ ឥស្សរភាព សេរីភាព ក្នុងវិត្តណាមួយឡើយ ត្រូវបានទទួលតែសេចក្តីចង្អៀតចង្អល់ទើសទែង ស្រែកថ្ងូរទ្រហោយំ ក្រៃលែងជាងទាសៈចំពោះរូប ដែលត្រូវនាយចៅហ្វាយកាត់ផ្តាច់សិទ្ធិ និងដណ្តើមយកប្រយោជន៍នោះទៅទៀត ។ ព្រោះថាជាតិដែលត្រូវគេគ្រប់សង្កត់នោះ មិនមែនចំពោះតែមនុស្សមួយរូប ៗ ឡើយ សូម្បីមនុស្សដែលជាទីស្រឡាញ់ ជាទីគោរពរាប់អានទាំងអស់ ក៏ត្រូវគេគ្រប់សង្កត់ផងដែរ ទាំងត្រូវរងទុក្ខវេទនាវែនសាហាស រហូតទៅដល់កូន ដល់ចៅ ៗ ល ៗ ផងទៀត ឥតមានកំណត់ថាកាលណាទីផុតឡើយ ។ ចំណែកទាសៈចំពោះរូបដែលត្រូវគេគ្រប់សង្កត់នោះ ក៏ចំពោះតែរូបមនុស្សមួយ សូម្បីនឹងបានទទួលទុក្ខលំបាក ក៏ត្រឹមតែ ១ អាយុខ្លួនឯងប៉ុណ្ណោះ ។

(មានត)

# រឿងសាមកុក

## កណ្ឌទី ១៥

### ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នករាងវៃឆ្លាសបើបានអាន
នឹងបេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

ឯលីប៉ោកាលដឹងថា ទ័ពអ៊ួនសុតលើកមកប្រាំងជួរហ្នោះ ក៏ឲ្យហៅតាន់កុង, តាន់គុយ, តាន់តេង នឹងនាយទាហានទាំងពួងមកប្រឹក្សាថា គ្រានេះអ៊ួនសុតលើកទ័ពមកជំយ៉ាងពន្លឹក ហើយញែកគ្នាទៅវាយស្រុកបំណុះរបស់យើងទាំងអស់ តើអ្នកទាំងឡាយនឹងគិតប្រការដូចម្ដេច? ។ តាន់កុងឆ្លើយថា ដែលកើតហេតុទាំងនេះ ក៏ព្រោះតាន់គុយនឹងតាន់តេង ២ នាក់ពុកនឹងកូន ឃាត់មិនឲ្យលោកលើកកូនក្រមុំឲ្យអ៊ួនសុត ហើយឃុបឃិតចូលគំនិតគ្នាទៅនិយាយនឹងប៊ួចូ ៗ ក៏តាំងតាន់តេងជានាហ្មឺនមានបណ្ដាសក្ដិ ហេតុនេះ សុំឲ្យលោកចាប់ខ្លួនតាន់តេងនឹងតាន់គុយ

បញ្ជូនទៅឲ្យអ៊ុនសុត ហើយសំដែងរឿងរ៉ាវទាំងប៉ុន្មានឲ្យអ៊ុនសុតអស់សេចក្ដីសង្ស័យ ប្រហែលអ៊ុនសុតនឹងលើកទ័ពត្រឡប់ទៅវិញ ។ លីប៉ោយល់ឃើញត្រូវ ក៏បង្គាប់ទាហានឲ្យទៅចាប់ខ្លួនតាន់គុយនឹងតាន់តេងទាំង២នាក់យកទៅសម្លាប់ ។

តាន់តេងដឹងថា លីប៉ោបង្គាប់ឲ្យចាប់ខ្លួន ក៏ចូលទៅជួបនឹងលីប៉ោនិយាយហើយសើចចំអកឲ្យលីប៉ោថា ពីដើមខ្ញុំបាទយល់ថា លោកជាមនុស្សមានសតិបញ្ញាស្គាល់ការខុសត្រូវមាំមួន ឥឡូវសង្កេតទៅឃើញគំនិតនឹងដំរេះប្រាជ្ញារបស់លោកទន់ខ្សោយពេកណាស់ ចុះលោកទៅញញើតខ្លាចអ៊ុននឹងចំនួនកងទ័ពអ៊ុនសុត ៧ កងប៉ុណ្ណេះ ឧបមាដូចជាស្មៅ ៧ ក្ដាប់នៅជិតមាត់គោ នឹងទំពាស៊ីក៏អស់ដោយងាយណាស់ ដូចរឿងនេះបើនឹងគិតតស៊ូក៏ឃើញថាកងទ័ពអ៊ុនសុតនោះ នៅមិនល្មមនឹងគំនិតរបស់ខ្ញុំបាទទេ ។ លីប៉ោសួរថា អ្នកនឹងគិតធ្វើឧបាយដូចម្ដេច? ក៏ឲ្យរិះគិតធ្វើឲ្យបានទៅចុះ បើគិតយកអាសាចេញទៅតស៊ូនឹងអ៊ុនសុតបាន យើងក៏ព្រមលើកទោសទាំងអាពុកនឹងកូន ។ តាន់គុយជំរាបថា ប្រសិនបើលោកស្ដាប់ពាក្យខ្ញុំបាទ ។ នឹងជានាស្រុកឈីជីវទុកមិនឲ្យកើតមានសេចក្ដីអន្តរាយឡើយ ។ លីប៉ោសួរថា គំនិតរបស់អ្នកនឹងគិតធ្វើដូចម្ដេច? ។ តាន់គុយជំរាបថា ទាហានអ៊ុនសុតច្រើនក៏មែនពិតហើយតែថាសុទ្ធតែជាមនុស្សផ្ដេសផ្ដាសមិនចំណានក្នុងការសឹកសង្គ្រាម ទាំងខ្លួនអ៊ុនសុតសោត

កំមិនសូវទុកចិត្តប៉ុន្មាន, ឯតាហានក្នុងស្រុកយើងសុទ្ធតែជាមនុស្សគួរទុកចិត្តបាន . បើយើងនឹងលើកចេញទៅច្បាំងនឹងអ៊ួនសុតវេលាណាគង់តាហានខាងយើងនឹងមានជ័យជំនះ ឯគំនិតខ្ញុំបាទដែលនឹងគិតរក្សាស្រុកឈើទាលនេះត្រូវតែស៊ូនឹងអ៊ួនសុតមានឧបាយទៅទៀត ។ លីប៉ោស៊ួថាកលឧបាយរបស់អ្នកគិតធ្វើដូចម្តេចខ្លះ? ។

តាន់គុយដំកបថា ហាន់សៀមនឹងអៀវហាង ២ នាក់នេះ ពីដើមនៅធ្វើខ្ញុំរាជការព្រះចៅហៀនគេ លុះចូលធ្វើទុកបៀតបៀនគ្មានទីពឹងពុំនាក់ក៏នាំគ្នារត់មកពឹងបុណ្យអ៊ួនសុត ។ ក៏មិនបានដប់លៀងតាមគុណបំណាច់នឹងជំរះប្រាជ្ញាឲ្យដល់ខ្នាត ខ្ញុំបានឃើញថា ហាន់សៀមនឹងអៀវហាង មិនមែនតាំងចិត្តទៀងត្រង់នឹងអ៊ួនសុតប៉ុន្មាន សុំឲ្យលោកមានសំបុត្រជាសម្ងាត់ទៅដល់ហាន់សៀមនឹងអៀវហាងថា បើវេលាណាខ្លួនលោកនឹងអ៊ួនសុតចេញច្បាំងនឹងគ្នា ឲ្យហាន់សៀមនឹងអៀវហាងគិតធ្វើឧបាយជាកលសឹកខាងក្នុង ហើយឲ្យលោកមានសំបុត្រទៅដល់ឡេវពីឲ្យឡេវពី, គួនអ៊ូ, គៀវហ៊ុយលើកទ័ពមកជួយវាយខ្នងពីក្រោយទ័ពអ៊ួនសុត មុខជាអ៊ួនសុតនឹងបរាជ័យមិនខាន ។

លីប៉ោយឃើញត្រូវ ក៏ធ្វើសំបុត្រចាត់ប្រើតាន់គេងឲ្យលបចេញទៅឲ្យហាន់សៀមនឹងអៀវហាង ដែលលើកទ័ពទៅវាយស្រុកហែហ៊ូនឹងស្រុកជុនស៊ួ ហើយប្រើតាហានឲ្យកាន់សំបុត្រចូលទៅក្រុងហ៊ូគោ ជូន

ដំណឹងដល់ប៊ូត្តូ ១ ច្បាប់ទៅផល់ឡៅពីនៅស្រុកអ៊ីជីវ ១ ច្បាប់ ៗ លុះតាន់តេងបានសំបុត្រនឹងតាហាន ៣ នាក់ ក៏លបចេញទៅស្រុកហៃហ៊ឺមុន, ទទួលហាន់សៀមៈលីកទ័ពទៅដល់ស្រុកហៃហ៊ឺ តាំងបន្ទាយនៅក្រៅកំផែងស្រុក ៗ តាន់តេងក៏ចូលទៅជួបនឹងហាន់សៀមក្នុងបន្ទាយ ហាន់សៀមក៏សួរតាន់តេងថា អ្នកឯងនេះក្រែងជាពួកម៉ាកលីប៉ោទេ ហេតុម្តេចក៏ចូលមកក្នុងបន្ទាយយើង? ៗ តាន់តេងសើចហើយថាខ្ញុំជាខ្ញុំព្រះចៅហៀនតេទេ ហេតុម្តេចអ្នកថាជាពួកម៉ាកលីប៉ោវិញ ខ្ញុំនឹងអ្នកក៏ដូចគ្នា ព្រោះអ្នកបាននៅធ្វើជាខ្ញុំរាជការព្រះចៅហៀនតេ កាលទ្រង់សោយទុក្ខលំបាកនៅទីគយគួនតុង អ្នកក៏បានជួយឲ្យព្រះអង្គរួចចាកទុក្ខ ខ្ញុំអ្នកក៏នៅមានគុណបំណាច់នឹងផែនដី ដូចជាបក្សីបានសម្បុកនឹងទ្រទំហើយម្តេចឡើយក៏អ្នកមកលះបង់សម្បុកទ្រនំ មកនិយមនៅនឹងអ៊ួនសុតជាមនុស្សអកតញ្ញូក្បត់ផែនដី ខ្ញុំឃើញការមិនគប្បីដូច្នេះបានជាចូលមកដើម្បីនឹងដាស់តឿនសតិអ្នក ព្រោះខ្ញុំឃើញថា បើអ្នកនឹងដេកនៅក្នុងមុងអ៊ួនសុតតទៅ អ្នកក៏គង់មានសេចក្តីទុក្ខភ័យលំបាកទៅខាងមុខ បើអ្នកចង់ឲ្យរួចចាកទុក្ខជាសុខតទៅត្រូវតែគិតឲ្យហើយជាមុន ទើបផុតរួចចាកកណ្តាប់ដៃអ៊ួនសុតបាន ៗ

ហាន់សៀមបានឮតាន់តេងសំដែងពីរឿងដើមទាំងប៉ុន្មាន ក៏មានសេចក្តីរលឹកនឹកឃើញសព្វគ្រប់ ដាក់មុខស្ងួតស្ងប់ហើយដកដង្ហើមធំ

និយាយថា ខ្ញុំសព្វថ្ងៃនេះក៏រិះគិតមិនកើតដែរ តែថាបានជាដែលខ្លួនមក នៅទីនេះអ៊ុនសុតហើយ មិនដឹងឡើយដែលនឹងគិតដូចម្ដេច ការនេះស្រេច តែអ្នកជួយគិតខ្ញុំផង ៗ គាន់គេងយល់អធ្យាស្រ័យហួតយកសំបុត្រលីះប៉ោ ហុចឲ្យទៅហាន់សៀមៗ មើលដឹងសេចក្ដីច្បាស់ក៏ផ្ទាស់ចិត្តទទួលពាក្យរងថា ការនោះកុំព្រួយ ចាំខ្ញុំទៅរិះគិតនឹងអៀវហាងទៀត អ្នកចូរត្រៀតទៅជំរាប លីប៉ោចុះថា ការនោះខ្ញុំទទួលជាធុរៈហើយ បើកាលណាលីប៉ោចូល វាយត្រង់គយនោះ ខ្ញុំនឹងជួយធ្វើការនោះឲ្យសម្រេច ៗ គាន់គេងមាន សេចក្ដីត្រេកអរជាពន្លឹក ហើយក៏ធ្វើសេចក្ដីគារវៈគំនាប់ហាន់សៀម ហើយលាចេញទៅយកសេចក្ដីនោះមកជំរាបលីប៉ោគ្រប់ប្រការ ៗ

ខណៈនោះ លីប៉ោប្រមូលសេនាទាហានបានមួយម៉ឺនថ្វាយ បំបែកទ័ពចេញជា ៤ កង ឲ្យកោស៊ុនលើកទ័ពទៅជួយស្រុកសៀវផាយ ច្បាំងនឹងកៀវសេង ១ កង, ឲ្យគាន់កុងលើកទ័ពទៅជួយស្រុកគិនគោ ច្បាំងនឹងគាន់គី ១ កង, ឲ្យតៀវសៀវលើកទៅជួយស្រុកឡូងអៀ ច្បាំងនឹងលុយប៉ុក ១ កង, ឲ្យស៊ុនហៀន ង៉ុយសុកលើកទៅជួយស្រុកកៀតសិក ច្បាំងនឹងគាន់ឡាន់ ១ កង ខ្លួនលីប៉ោប្រមូលសេនាទាហានដែលមានថ្វីដៃ លើកចេញទៅតាំងបន្ទាយនៅខាងក្រៅកំពែងស្រុក ចម្ងាយប្រហែល ៣០០ សិន (១២ គី ម.) ៗ លុះតៀវហ៊ុនលើកទ័ពមកដល់បន្ទាយលីប៉ោ ក៏ប្រើទាហានឲ្យចូលទៅហៅលីប៉ោចេញមកច្បាំងគ្នា ៗ (មានត)

# រឿងអារក្សថ្លែងរឿងម្ភៃប្រាំ

## លោករ៉ាយ-ប៊ុក ក្រមការ នៅក្រុមពុទ្ធសាសនបណ្ឌិត្យ

*ប្រែពីបារាំងមកជាខ្មែរ*

(តមក)

---

## រឿងទីដប់ប្រាំ

*អារក្សក្រាបទូលថា: បពិត្រមហារាជ! នៅលើគិរីមួយឈ្មោះហិម-ចល: (Himachal) គេបានស្ថាបនានូវព្រះរាជធានីមួយជាមណ្ឌល នៃពួកគន្ធព្វ (ទេវតារបាំ) ដែលមានព្រះបាទជិមុតកេតុ* (Jimutkètu) *សោយរាជសម្បត្តិនៅទីនោះ ។ ដោយទ្រង់មានព្រះរាជបំណងចង់បានព្រះរាជបុត្រមួយព្រះអង្គ. ព្រះមហាក្សត្រអង្គនេះទ្រង់ក៏បានធ្វើសក្ការបូជាជានិច្ចនូវចំពោះទេវតានាម កល្បព្រឹក្ស* (Kalpa-Prisksh) ។ *មានមួយថ្ងៃទេវរូបនេះ មានព្រះទ័យសោមនស្សពន់ពេក, ហើយក៏មានទេវវាចាទៅកាន់ព្រះមហាក្សត្រថា: "បពិត្រមហារាជ! យើងខ្ញុំបានឃើញច្បាស់នូវករណីយកិច្ច ដែលមហារាជធ្វើចំពោះខ្ញុំ, យើងខ្ញុំអនុញ្ញាតឲ្យទ្រង់សូមសេចក្តីអនុគ្រោះអ្វីមួយ, យើងខ្ញុំនឹងថ្វាយទ្រង់តាមព្រះរាជបំណង" ។*

*ព្រះមហាក្សត្រទ្រង់មានព្រះបន្ទូលថា: "សូមទ្រង់ព្រះមេត្តាធ្វើ-អំណោយនូវព្រះរាជបុត្រមួយអង្គដើម្បីនឹងតសន្តតិវង្ស សោយរាជសម្បត្តិស្នងយើងខ្ញុំតទៅអនាគត" ។*

ទេវរូបនោះក៏មានទេវបញ្ជាថា: "សូមឲ្យបានសម្រេចតាមព្រះរាជបំណង" ។

មិនយូរប៉ុន្មាន ព្រះអគ្គមហេសីព្រះអង្គទ្រង់មានគភ៌ ហើយក៏ប្រសូតព្រះរាជបុត្រ ។ ព្រឹត្តិការណ៍នេះ, ព្រះមហាក្សត្រទ្រង់ត្រាស់បង្គាប់ឲ្យរៀបធ្វើពិធីជាឧឡារិក ហើយទ្រង់មានព្រះរាជហឫទ័យសោមនស្សពន់ពេក ។ ក្នុងពិធីបុណ្យនោះ ទ្រង់ក៏បានត្រាស់បង្គាប់ឲ្យយករបាំក្នុងជួរ្យតន្ត្រី, ព្រះរាជទានអំណោយជាច្រើនបែបច្រើនយ៉ាង, ព្រមទាំងធ្វើបុណ្យកុសលក្នុងសាសនាថែមទៀតផង ។ ទ្រង់មានព្រះបន្ទូលឲ្យហៅព្រាហ្មណ៍មកដើម្បីនឹងដាក់ព្រះនាមព្រះរាជបុត្រ ហើយព្រាហ្មណ៍ទាំងនោះបានដាក់ព្រះនាមថា: ជិមុតពហ័ន (Jimutbahan) ។ លុះព្រះរាជបុត្រមានព្រះជន្មាយុដប់ពីរឆ្នាំ ទ្រង់ត្រូវគោរពចំពោះព្រះសិរៈជាមុន ។ ទ្រង់បានអប់រំនូវវិទ្យាសាស្ត្រទាំងអស់ ហើយមានព្រះប្រាជ្ញាដ៏មុតមាំខាងការពិចារណា, មានព្រះទ័យម៉ឺងម៉ាត់ក្លាហាន, ក្លៀវក្លា ព្រះទ័យទន់ភ្លន់ខាងសាសនា យល់គិតការពារក្រៅសត្វយ៉ាង ។ ចំពោះព្រះប្រាជ្ញាគ្មានអ្នកណាអាចប្រៀបធៀបនឹងព្រះអង្គបានឡើយ ហើយប្រជារាស្ត្រទាំងអស់ក្នុងព្រះរាជអាណាចក្រ ក៏ប្រព្រឹត្តករណីយកិច្ចសព្វៗខ្លួន ។ ព្រះអង្គម្ចាស់ទ្រង់ស្ថិតនៅក្នុងយុវនភាព តែទ្រង់គោរពរាប់អានជា

និវត្ត៍ នូវទេវតាឈ្មោះ កល្បព្រឹក្ស ។ ទេវរូបនេះមានទេវបញ្ញាថា: “ទ្រង់មានព្រះទ័យប្រាថ្នាអ្វី សឹងបានតាមប្រាថ្នា” ។

ព្រះអង្គម្ចាស់ទ្រង់តបទៅនឹងទេវតាវិញថា: “បើទ្រង់សព្វព្រះរាជហឫទ័យនឹងខ្ញុំ សូមទ្រង់ធ្វើឲ្យទុព្ភិក្ខភ័យជៀសចេញឆ្ងាយពីប្រជារាស្ត្ររបស់ខ្ញុំ ហើយឲ្យប្រជារាស្ត្ររបស់ខ្ញុំមានភោគទ្រព្យស្មើៗ គ្នា” ។

ទេវតាកល្បព្រឹក្សទ្រង់អនុគ្រោះព្រះអង្គម្ចាស់តាមព្រះរាជបំណង ហើយប្រជារាស្ត្រសុខស្រួលពន់ពេក ទាល់តែគ្មានអ្នកណាចង់ប្រតិបត្តិតាមព្រះបន្ទូលព្រះអង្គ ព្រមទាំងគ្មានធ្វើការអ្វីសោះឡើយ ។ ពួកប្រជារាស្ត្រក្នុងព្រះរាជអាណាចក្រ ត្រឡប់ទៅជាមានចរិយាកាចសាមាន្យ ដោយព្រះរៀមនឹងព្រះរាជវង្សានុវង្សបានញុះញង់ គឺថាប្រជារាស្ត្រទាំងនោះគិតថា ព្រះបរមរាជបិតានឹងព្រះរាជបុត្រទាំងពីរព្រះអង្គ ទ្រង់កាន់សាសនាជាប្រមុខ, ហើយប្រជារាស្ត្រលែងស្តាប់ធ្វើតាមព្រះរាជឱង្ការ, យើងនឹងព្រះរាជបុត្រត្រូវតែចាប់ព្រះមហាក្សត្រយកទៅឃុំឃាំង ហើយដណ្តើមយករាជសម្បត្តិ ។

ព្រះមហាក្សត្រទ្រង់មិនបានជ្រាបនូវរឿងនោះ ទ្រង់ក៏មិនបានប្រុងប្រយ័ត្នការពារព្រះអង្គឡើយ, ស្រាប់តែពួកឧទ្ទាមចាត់កងទ័ពព័ទ្ធព្រះបរមរាជវាំង ។

កាលទ្រង់ផ្ដាំបន្ទូលដំណឹងនេះ, ទ្រង់ក៏បានសួរព្រះរាជបុត្រថា: "តើយើងគិតយ៉ាងណា?" ។

ព្រះអង្គម្ចាស់ទ្រង់ក្រាបបង្គំទូលព្រះវរបិតាថា "សូមព្រះវរបិតាគង់នៅទីនេះហើយ ទ្រង់កុំខ្វាយខ្វល់ឡើយ, ទូលបង្គំនឹងយកពលកាពនៃគុណសម្បត្តិ ព្រះវរបិតាទៅផ្ចាញ់ពួកខ្មាំងឲ្យបានជោគជ័យ" ។

ព្រះមហាក្សត្រទ្រង់មានព្រះបន្ទូលទៅព្រះរាជបុត្រថា: 'ឱកូន! រូបកាយនេះជាអនិច្ចាធម៌ ហើយភោគទ្រព្យក៏មិនទៀង, បើមានសត្វបដិសន្ធិ ទៀងតែសត្វនោះអនិច្ចកម្ម, ឥឡូវយើងត្រូវទុកដោយឡែកហើយយើងត្រូវចូលសិប់ទៅក្នុងសាសនាតែម្ដង, យើងមិនត្រូវប្រព្រឹត្តបាបអកុសលធំៗ ព្រោះតែសេចក្ដីស្នេហានៃរូបកាយ ហើយទីងព្រះរាជអាណាចក្រប៉ុណ្ណោះទេ; ព្រះមហាក្សត្រ យុធិស្ឋិរ: (yûdhishthir) ទ្រង់បានសោកស្ដាយជាច្រើនលើកច្រើនគ្រាអំពីសង្គ្រាមដែលសន្ដតិវង្ស "ការត" បានធ្វើពីអតីតកាលមក" ។

ព្រះរាជបុត្រទ្រង់ព្រះសណ្ដាប់នូវព្រះបន្ទូលព្រះវរបិតាហើយ ទើបទ្រង់ក្រាបទូលតបវិញថា: "ព្រះឱង្ការនៃព្រះវរបិតាពេញជាត្រូវមែន, ត្រូវលះបង់រាជសម្បត្តិឲ្យទៅព្រះរាជវង្សានុវង្ស ហើយទ្រង់យាងទៅធ្វើឥសី" ។

លុះបានសម្រេចព្រះរាជបំណងហើយ. ព្រះមហាក្សត្រទ្រង់ត្រាស់បង្គាប់ឲ្យអញ្ជើញព្រះជេដ្ឋានិងព្រះអនុជ ព្រមទាំងព្រះភាគិនេយ្យមក, ទ្រង់ព្រះរាជទានទូវរជ្ជាភិបាល រួចព្រះវរបិតានឹងព្រះរាជបុត្រទ្រង់ចេញពីព្រះបរមរាជវាំងទាំងពីរព្រះអង្គតម្រង់ទៅលើភ្នំតូចមួយឈ្មោះ មលយចល: (Malayachal) ទ្រង់បានឲ្យសាងអាស្រមហើយក៏គង់នៅទីនោះ ៗ

ព្រះអង្គម្ចាស់ជិមុតពហ័ន ទ្រង់បានរក្សាមេត្រីភាពនឹងបុត្របុសីម្នាក់ ៗ មានកាលមួយថ្ងៃ ព្រះអង្គម្ចាស់ទ្រង់បានត្រាច់ទៅក្រសាលលើភ្នំតូចនោះ ជាមួយនឹងបុត្របុសី ទ្រង់បានទតទៅឃើញបូជនីយដ្ឋានមួយដែលគេសាងសម្រាប់ព្រះនាងភវានី (Bhavâni) ៗ នៅក្នុងបូជនីយដ្ឋាននេះ. មានព្រះរាជបុត្រីព្រះមហាក្សត្រមួយអង្គ ទ្រង់កំពុងច្រៀងចំពោះព្រះភក្ត្រនាងទេវតា ដោយផ្ញាត់ចាប៉ីផង ៗ ព្រះចក្ខុព្រះនាងទតទៅយល់ព្រះអង្គម្ចាស់ ជិមុតពហ័នហើយ ទ្រង់ទាំងពីរក៏ក្តុកក្តួលក្នុងព្រះទ័យដោយកាមតណ្ហាពន់ពេក, តែព្រះអង្គម្ចាស់ក្សត្រី ទ្រង់ទំទប់នូវមនោសញ្ចេតនារបស់នាង, ក៏វិលត្រឡប់ទៅកាន់ព្រះបរមរាជវាំងវិញ ៗ ចំណែកព្រះអង្គម្ចាស់ជិមុតពហ័នខ្មាសអៀនពន់ពេក ក៏វិលត្រឡប់ទៅកាន់អាស្រមវិញជាមួយនឹងបុត្របុសី ហើយទ្រង់ក៏ផ្ទុំលក់ក្នុងយប់នោះព្រមទាំងបុត្របុសីដោយគន្វលក្នុងព្រះទ័យជាខ្លាំង ៗ លុះដល់បុព្វណ្ហសម័យ. ព្រះអង្គម្ចាស់ក្សត្រីទ្រង់ស្តេចទៅកាន់បូជនីយដ្ឋាន ព្រះអង្គម្ចាស់ជិមុតពហ័នក៏យាង

ទៅទីនោះដែរ ។ ព្រះអង្គម្ចាស់ទ្រង់ទតយល់ព្រះនាងហើយ ក៏ទ្រង់មានបន្ទូលសួរពីព្រះជន្មព្រះនាង ។

ព្រះនាងក្រាបទូលថា: "ខ្ញុំនាមនាង មលយវតី (malayavati) ជាព្រះរាជបុត្រីព្រះបាទមលយកេតុ (Malayakêtu) ហើយនាងខ្ញុំនៅកញ្ញវ័យនៅឡើយ" ។

កាលព្រះនាងក្រាបទូលព្រះអង្គម្ចាស់រួចហើយ ក៏មានបន្ទូលសួរទៅព្រះអង្គម្ចាស់វិញថា: "អ្នកកម្លោះមកពីណា? ឈ្មោះអ្វី?" ។

ព្រះអង្គម្ចាស់ទូលតបទៅព្រះនាងវិញថា: "ខ្ញុំឈ្មោះជិមុតពាហ័ន ជាព្រះរាជបុត្រព្រះបាទជិមុតកេតុ មហាក្សត្រ នៅពិទ្យធរ: (Bidyadharas), ព្រះវរបិតាខ្ញុំបាន យាងមកគង់ទីនេះជាមួយនឹងខ្ញុំ ក្រោយដែលគេដណ្តើមយករាជសម្បត្តិ" ។ នាងកិលៀងម្នាក់ក្រាបទូលព្រះនាងឲ្យជ្រាបសព្វគ្រប់ប្រការ នូវព្រះបន្ទូលព្រះអង្គម្ចាស់ ។ ព្រះនាងទ្រង់ព្រួយព្រះហឫទ័យពន់ពេក, វិលត្រឡប់ទៅព្រះបរមរាជវាំងវិញ ។ ដល់ពេលយប់, ព្រះនាងទ្រង់ព្រះតម្រិះអំពីរឿងនេះ ក៏ទ្រង់ផ្ទំលក់ទៅ ។ នាងសហជីវនីកាលបានយល់ព្រះនាងព្រួយព្រះទ័យពន់ពេក ក៏ទៅក្រាបបង្គំទូលព្រះបរមរាជមាតា ។ ទ្រង់ក៏ក្រាបបង្គំទូលព្រះមហាក្សត្រថា: 'សូមទ្រង់ព្រះមេត្តាប្រោស! កូនស្រីអាយុល្មមរកស្វាមីឲ្យហើយ, ហេតុម្តេចក៏ព្រះអង្គទ្រង់មិនមានព្រះតម្រិះរកបុរសណាល្មមឲ្យជាស្វាមី កូនស្រីយើង?" ។

ព្រះមហាក្សត្រទ្រង់ព្រះសណ្ដាប់ហើយក៏មានព្រះបន្ទូលបាត់ឲ្យទៅហៅព្រះរាជបុត្រព្រះនាម មិត្រាវសុ (Mitravasu) ហើយទ្រង់ត្រាស់បង្គាប់ឲ្យទៅរកស្វាមីឲ្យនាង ។

ព្រះអង្គម្ចាស់ទ្រង់ក្រាបបង្គំទូលព្រះវរបិតាថា: "ទូលព្រះបង្គំបានដំណឹងថា ព្រះបាទជីមុតកេតុនឹងព្រះរាជបុត្រជីមុតពាហន ទ្រង់ស្ដេចយាងមកកាន់ទីនេះ ក្រោយដែលបញ្ចេញហោលរាជសម្បត្តិ" ។

ព្រះបាទមលយកេតុទ្រង់មានបន្ទូលថា: "បិតានឹងឲ្យកូនស្រីទៅព្រះអង្គម្ចាស់ជីមុតពាហន" ។

រួចទ្រង់ត្រាស់បង្គាប់ព្រះរាជបុត្រឲ្យទៅរកព្រះអង្គម្ចាស់ជីមុតពាហន ។ ព្រះរាជបុត្រទ្រង់ស្ដេចទៅដល់ក្រាបបង្គំទូលព្រះបាទជីមុតកេតុ នូវព្រះរាជបំណងនៃព្រះបាទមលយកេតុជាព្រះវរបិតា ។

ព្រះបាទជីមុតកេតុទ្រង់ព្រះសណ្ដាប់ហើយ, ទ្រង់ក៏អនុញ្ញាត ឲ្យព្រះរាជបុត្រស្ដេចទៅជាមួយព្រះអង្គម្ចាស់មិត្រាវសុ ។ លុះដល់ព្រះអង្គម្ចាស់ទាំងពីរទ្រង់ស្ដេចទៅដល់ចំពោះព្រះភក្ត្រព្រះបាទមលយកេតុ ៗ ក៏ទ្រង់ត្រាស់បង្គាប់ឲ្យធ្វើពិធីព្រះរាជសមរស ព្រះអង្គម្ចាស់នឹងព្រះនាងតាមទំនៀមគន្ធរ្វ «Gândharva» ។

(មានត)

# រឿងស្លាប់ព្រោះជាតិ

មាន ៣ ឈុត

លោកគង់-លឹម និស្សិតសាលាគរុវិជ្ជា ភ្នំពេញ តែង

(តពីលេខ ១២ ឆ្នាំ ១៩៥២)

---

## ភាគទី ៤

## ភគា វណ៌្ណនារី ភគី

### ភាគី

ប៉ាអង្គុយធ្វើអ្វីហ្នឹង? ចុះប្អូនខ្ញុំថ្វីក៏ដេកស្ដឹងស្ដុកយ៉ាងនេះ? ។ អូន! អូន! ប៉ាប៉ា! ម្ដេចក៏បាត់មាត់បាត់កស្ងាត់ស្ងៀមយ៉ាងដូច្នេះ? (ដើរទៅមើលផ្ទរស្រាប់តែឃើញអក្សរស្លាកថា ម្ដាយស្លាប់)

យើប៉ា! ម៉ាក់ខ្ញុំស្លាប់! ស្លាប់ពីថ្ងៃណា ប៉ា? ម៉ាក់អើយ! ម៉ាក់ទទួលមរណភាពចោលខ្ញុំហើយ! អ្នកម្ដាយទុកឲ្យខ្ញុំក៏ព្រាវេទនាក្នុងលោកនេះហើយ, លោកឪពុក! ម្ដេចក៏លោកមិនប្រាប់ខ្ញុំ? ម្ដេចក៏លោកឪពុកចាំលាក់ធ្វើអ្វី? ។ អ្នកម្ដាយអ្នកគ្មានទឹកអាណិតដល់កូនបន្តិចទេ; អ្នកម្ដាយអើយ! ខ្ញុំលែងបានឃើញមុខអ្នកម្ដាយទៀតហើយ ។ លោកប៉ា! លោកប៉ាជាមនុស្សអាក្រក់ណាស់, ម្ដាយខ្ញុំស្លាប់ ប៉ាមិនប្រាប់ខ្ញុំទេ ។ ម៉ាក់អើយខ្ញុំមិនចង់នៅរស់ទេ ។

ភាគា

ឱព្រះអើយ! មួយទៀតហើយ! កូនប្រុសមាសឪពុក! ចូរកូនអាណិតដល់ចិត្តឪពុកផង ឪពុកតឹងកង្ទ្រូងណាស់! ឪពុកទទួលកំហុសទាំងអស់ ឪពុកទទួលទោសទាំងអស់កូន! ចូរកូនកុំប្រកាន់ទឹងទឹងឪពុកធ្វើអ្វី ។

ភាគី

លោកឪពុកមិនគួរធ្វើយ៉ាងដូច្នេះសោះ! បើទុកជាម្ដេចម្ដា ក៏គួរតែលោកឪពុកប្រាប់ខ្ញុំជាកូនឲ្យដឹងផងដែរ ។ លោកឪពុកមិនគួរទីងលាក់យ៉ាងដូច្នេះទេ! ។ បើប្រាប់ខ្ញុំមក ខ្ញុំឥតមានថាអ្វីទេ ធ្វើម្ដេចរូបមនុស្សយើង តែងតែមានព្រាត់ប្រាសទិវាសចាកចោលគ្នា យ៉ាងដូច្នេះជាធម្មតា រូបណាក៏ដូចជារូបណាដែរ កើតមកជាមនុស្សក្នុងវដ្ដសង្សារពិភពលោក សន្និវាសយើងនេះ មិនអាចនរណាមួយចៀសឲ្យផុតអំពីសេចក្ដីស្លាប់បានទេ! ។ កុំថាតែយើងជាមនុស្សបុថុជ្ជន ទុកជាព្រះសម្មាសម្ពុទ្ធជាម្ចាស់ក៏ដោយ គង់តែព្រះយាងចូលនិព្វានដែរ ។

ភាគា

ឱកូនមាសឪពុក! អ្នកយល់ត្រូវល្អណាស់ ។ រឿងនេះឪពុកមិនបានប្រាប់កូនឲ្យដឹងព្រោះឪពុកអាណិតកូនណាស់ ។ បើកាលណាប៉ាប្រាប់ឯងទៅ មុខជាឯងនឹងកើតទុក្ខ ហើយឯងនឹងប្រកបការរៀនសូត្រមិនបានចម្រើន, ហេតុនេះហើយបានជាប៉ាមិនប្រាប់ឯង ។

## ភាគី

លោកឪពុក! សេចក្ដីទុក្ខសោកកើតមានឡើង ចំពោះរូបមនុស្សណាដែលគ្មានបេះពិចារណាគិតឲ្យឃើញវែងឆ្ងាយទេ ។ បើកាលណាគេគិតពិចារណាឲ្យវែងឆ្ងាយតាមគន្លងច្បាប់ព្រះសម្មាសម្ពុទ្ធទៅចុះ ប្រហែលជាគេមិនសូវកើតទុក្ខប៉ុន្មានទេប៉ា! ។

## ភាគា

នែកូន! ឯងត្រូវត្រឡប់ទៅហៅជីដូនឯងមក ឲ្យជួយមើលនាងវណ្ណ៍នារីផង ថាវាយំសន្ធប់បាត់មាត់បាត់កទៅហើយ ឲ្យគាត់ឆាប់អញ្ជើញមក ។ កូនខ្ញុំក្មេងតែខ្លួនទេ! តែបេះពិចារណាគិតឃើញវែងឆ្ងាយល្អណាស់, បេះយកផ្លូវធម៌មកនិយាយពន្យល់ខ្ញុំផង ។ ឯសេចក្ដីទុក្ខសោករបស់វាក៏ពុំសូវកើតមានឡើងប៉ុន្មានដល់រូបវាទេ វាមិនកើតទុក្ខប៉ុន្មានទេ ។ តូចតែខ្លួន តែគំនិតបេះគិតទៅវែងឆ្ងាយ ។

កូន! វណ្ណ៍នារីកូន! កូនមាសឪពុក! កូនក្រោកឡើង អាណិតប៉ាទៅកូន! កុំយំកុំសោកច្រើនពេក! នាំឲ្យទៅជាឈឺថ្កាត់ កុំឲ្យប៉ាព្រួយចិត្តច្រើនពេក ។ ធ្វើម្ដេចរូបមនុស្សយើងតែកើតឡើងមកហើយតែងតែវិនាសទៅវិញជាធម្មតា មិនដែលមានរូបណាមានខ្លឹមសារទឹងស្ថិតថេរទៅវែងឆ្ងាយនោះទេ ។

វណ្ណ៍តារី

(និយាយតាំងយំ) ខ្ញុំចង់តែក៏យប៉ាឯងឲ្យស្លាប់ទៅជាមួយនឹងម៉ាក់ឥឡូវហ្នឹង, ស្អប់ណាស់គ្រាន់តែម៉ាក់ខ្ញុំស្លាប់ ប៉ាឯងមិនប្រាប់ខ្ញុំឲ្យដឹងទេ, លាក់ណាស់! លាក់ទុកធ្វើអ្វី? ខ្លាចខ្ញុំសុំប៉ាឯងឬ?

ភាគា

ប៉ាខ្លាចកូនឯងកើតទុក្ខហើយឈប់លែងរៀន បានជាប៉ាមិនប្រាប់ឲ្យកូនដឹង ។

វណ្ណ៍តារី

ខ្ញុំលែងរៀនហើយប៉ា! ខ្ញុំលែងទៅផ្ទះហើយ! ។ ខ្ញុំនៅគេងនឹងផ្នូរម៉ាក់ហ្នឹងជាដរាប ប៉ាឯងទៅផ្ទះចុះ ។

ភាគា

កូនឯងមិនខ្លាចខ្មោចទេឬ? នៅហ្នឹងខ្មោចច្រើនណាស់ តែពេលបំឡើងសឹងមិនទាន់ទេ វាចេញដើរប្រវាត់ប្រវែងពេញព្រៃ ។

វណ្ណ៍តារី

ខ្មោចឯណានឹងហ៊ានលង បើខ្ញុំនៅដេកជាមួយនឹងម៉ាក់ ។

ភាគា

ឱ! ខ្មោចម៉ាក់ឯងលងហួសខ្មោចគេដទៃទាំងអស់, ឯងមិនឃើញទេ ពីព្រឹកមិញនេះទៅលងឯងកំពុងរៀន ឲ្យឃើញស្រស់ៗនឹងភ្នែក ។

ខ្មោចម៉ាក់ឯងហ្នឹងលង់សម្រើមហើយ! គង់ព្រៃហ្នឹងមានតែមួយទេ! ពីព្រោះខ្មោចនៅថ្មីៗ លង់សម្រើមណាស់ កុំនៅដេកៈជួរអ៊ីកូន! ដេកមិនបានទេ បើកូនទឹកណាស់ ចាំពេលល្ងាចត្រជាក់ ប៉ាឲ្យគេធ្វើម្ហូបអាហារចំណីមួយស្រាក់ឲ្យកូនយកមកសែនឲ្យម៉ាក់ឯង រាល់តែថ្ងៃក៏បានដែរ ។ តែឯងនៅដេកពុំបានទេ ។

រាគី

យី! វណ្ណនារី អូនដឹងខ្លួនហើយ, លោកប៉ា! អូនដឹងខ្លួនហើយឬ?

រាគា

វាទើបតែទឹងដឹងខ្លួនអំបាញមិញនេះទេ ។

រាគី

ស្ងាប់ហើយ លោកយាយខំរត់ទៅរកហៅពេទ្យបាត់ទៅហើយ ។

រាគា

បើដូច្នេះ ឯងរត់ទៅដំណាបលោកយាយឯងឲ្យឆាប់ទៅ! ថានាងវណ្ណនារីដឹងខ្លួនហើយ! កុំឲ្យគាត់ភ័យពេក ។

នៃកូនស្រីប៉ា! ប៉ាក្រុនលុតជង្គង់សំពះសូមខមាទោសទឹងអ្នកម្ដាយឯងទៅ កុំឲ្យម៉ាក់ឯងមានទោសនុកអ្វី! លើអំពើណាដែលម៉ាក់ឯងបានប្រព្រឹត្តកន្លងទឹងឯង ។ ហើយឯងក៏យ៉ាងដូច្នេះដែរ ត្រូវតែឯងសូម

ខមាទោសទឹងម៉ាក់ឯងវិញ លើសំដីណាក្រែងឯងបានពោលទ្រគោះបោះបោកឲ្យម៉ាក់ឯងកាលពីពេលមុន សូមកុំឲ្យមានទោសទាំងអស់គ្នា . . .

( នាងវណ្ណនារីក៏លុតជង្គង់ធ្វើតាមពាក្យឪពុក )

កូនស្រីប៉ា ! កូនពុំទាន់ដឹងទេ, មិនគ្រាន់តែឯងទាំងពីរនេះទេដែលពុំដឹងជាម្តាយឯងស្លាប់នោះ បំណែកប៉ាក៏យ៉ាងដូច្នេះដែរ ប៉ាឥតបានទាន់ដង្ហើមម៉ាក់ឯងទេ ប៉ាឥតបានឃើញមុខម៉ាក់ឯងបន្តិចទេ មិនដឹងជាស្រកសាច់ចុះស្គមប៉ុណ្មួយនៅដដែល, ប៉ាឥតបានដឹងទេ ពីព្រោះប៉ាមកមិនទាន់ដែរ ប៉ាមកដល់គេយកខ្មោចម្តាយឯងមកបញ្ចុះរួចទៅហើយ ៗ

កូនមិនទាន់ដឹងទេ, ម្តាយកូនឯងចិត្តស្មោះណាស់ ហ៊ានឲ្យប៉ាចេញទៅធ្វើសឹកសង្គ្រាម ក្នុងពេលដែលកំពុងមានជម្ងឺទៅហើយ ៗ សុខចិត្តស៊ូស្លាប់ដោយសារជាតិ, ឲ្យតែជាតិបានសុខ, មិនសុខចិត្តឲ្យប៉ានៅថែជម្ងឺទេ, ស៊ូនៅដេកថ្ងូរម្នាក់ឯង ឲ្យតែប៉ាបានទៅធ្វើការបំពេញកិច្ចដល់មាតុភូមិ ៗ ម៉ាក់ឯងស្លាប់យ៉ាងដូច្នេះ ប្រសើរណាស់កូន ! ៗ

វណ្ណនារី

ខ្ញុំចិត្តដូចម៉ាក់ខ្ញុំដែរប៉ា ! ដល់ខ្ញុំធំឡើង ៗ

(មានត)

# រឿងប៉ូល និង វីរស៊ីនី

## លោកផេង - ជ្រីវ សាស្ត្រាចារ្យនៅសាលាគរុវិជ្ជា ភ្នំពេញ

ប្រែរៀបរៀង

(តពីលេខ១២ ឆ្នាំ១៩៥២)

---

ហើយក៏បេះដូងទុំយ៉ាងស្អាតពីរបីផ្លែទៅឲ្យផង តែផ្លែដំណាំឯទៀតនៅកោះ ក៏មិនផ្ញើទៅទេ ដោយគិតថាបំណងចង់ឃើញផ្លែទាំងនោះនាំឲ្យនាងវិលត្រឡប់ឆាប់ ៗ ក៏សុំអង្វរឲ្យនាងត្រឡប់ឆាប់តាមពាក្យបន់ស្រន់នៃក្រុមត្រកូល តែខ្លួនក៏បន់ជាងគេ ដ្បិតក៏គ្មានសប្បាយសោះ នៅឆ្ងាយពីនាង ៗ

អាប៉ូលយកពូជដំណាំពីអឺរ៉ុបទៅសាបព្រោះដោយសេចក្តីមធ្យ័ត តែក៏យកចិត្តទុកដាក់ជាងគេ តែផ្កាវីយ៉ូឡែត និង ស្គ័ប្បឺយើ ព្រោះមានទំនងរឿងប្រហែលគ្នានឹងវីរស៊ីនី ៗ តែមិនដឹងជាស្អុយពន្លកតាមផ្លូវ ឬជាធាតុអាកាសនៅខាងស្រុកអាហ្វ្រិកមិនសូវល្អ បានជាគេឃើញដុះតែបន្តិចបន្តួច មិនបានដុះឲ្យច្រើនដូចចិត្តចង់ ៗ

ក្នុងពេលនោះ សេចក្តីប្រណែនដែលជាធម៌សម្រាប់ដើរទៅជំទាស់នៅពីមុខសេចក្តីសុខស្រួលនៃមនុស្សទាំងឡាយ បានផ្សាយដំណឹងក្នុងកោះ ជាដំណឹងដែលនាំឲ្យអាប៉ូលព្រួយពេក ៗ គឺមនុស្សអ្នកជិះកប៉ាល់ដែលកាន់សំបុត្រវីរស៊ីនីយកមកឲ្យនិយាយថា វីរស៊ីនី ជិតរៀបការ

ហើយៈ វាប្រាប់ឈ្មោះនាម៉ឺនដែលបំរុងយកវ៉ែស៊ីនធ្វើជាប្រពន្ធ អ្នកខ្លះនិយាយថា រឿងហ្នឹងប្រាកដណាស់ គេហ៊ានធ្វើជាសាក្សផង ៗ ដំបូងអាប៉ូលមិនជឿទេ ព្រោះថាពួកកប៉ាល់ជំនួញចេះតែក្មេងនិយាយបញ្ចោត ៗ តែដល់មនុស្សគ្រប់កោះបបួលគ្នារត់ទៅប្រាប់អាប៉ូល អំពីរឿងហ្នឹង ហើយនាំគ្នាត្អូញត្អែរអាណិត តែអាណិតប្រកបដោយសេចក្ដីប្រណែនៈនៅខាងក្នុង ម៉្លោះហើយ អាប៉ូលក៏អត់ទ្រាំជឿមិនបាន ៗ ម្យ៉ាងទៀត តាមក្នុងសាស្ត្រាខ្លះដែលវាៈមើល វាឃើញមានសេចក្ដីក្បត់ចិត្តខ្លះកើតមកពីពាក្យលេងសើច ហើយសាស្ត្រាទាំងនោះ មានរឿងទំនៀមទម្លាប់សុចរិតគួរសមក៏យកវ៉ាពីប្រទេសអឺរ៉ុប វាខ្លាចក្រែងកូននាងឡាគួរខូចខួរក្បាលទៅតាមគេ ភ្លេចសំដីដើម ៗ ការយល់ដូច្នេះនាំឲ្យវាកើតទុក្ខម្ដងទៀត ៗ ដែលនាំឲ្យវាជឿជាក់ក្នុងចិត្តជាដាច់ស្រេច មកពីមិនបានដំណឹងសោះក្នុងរវាងប្រាំមួយខែ ៗ

អាប៉ូលដែលបណ្ដោយឲ្យសេចក្ដីទុក្ខញាំញីដូច្នេះ ក៏ចេះតែមកឯផ្ទះខ្ញុំឲ្យខ្ញុំជួយគិតមើល ជួយពិចារណាមើល តើត្រូវធ្វើដូចម្ដេច ព្រោះខ្ញុំជាមនុស្សចាស់ (តាចាស់) យល់ការណ៍ច្រើន ៗ

ផ្ទះខ្ញុំសង់នៅមាត់ស្ទឹងដែលហូរតាមក្នុងវែង ចម្ងាយមួយគីឡូកន្លះពីផ្ទះអាប៉ូល ៗ នៅទីហ្នឹងហើយដែលខ្ញុំរកទទួលទានចិញ្ចឹមជីវិត តែម្នាក់ឯង គ្មានប្រពន្ធកូន គ្មានអ្នកបំរើឡើយ ៗ

ក្រៅពីសេចក្ដីសុខស្រួលដែលនៅជាមួយប្រពន្ធចិត្តស្លូតត្រង់គួរសម បើចង់កុំឲ្យសូវមានទុក្ខ ប្រាកដណាស់ ឃើញតែនៅរកស៊ីម្នាក់ឯង កុំឲ្យអ្នកណាមកជាពីរឡើយ ។ មនុស្សណាដែលរត់រកទីស្ងាត់ មកពីធុញទ្រាន់នឹងគ្នាច្រើន ។ មានមនុស្សច្រើនពួកណាស់ គួរលើកយកមកពន្យល់ ដែលធុញទ្រាន់នឹងយោបល់ មតិច្រើននឹងទំនៀមទម្លាប់ នឹងផ្លូវរាជការពេកនាំគ្នាទៅត្រកូលជាច្រើនដោយឡែក ដាច់ចិត្តនៅក្នុងទីស្ងាត់ ឬក៏ស៊ូនៅលីវ ។ ដូចពួកអេស៊ីប្ដជាន់ទាប ពួកក្រេកខាងស្រុកទាប: សព្វថ្ងៃនេះ ដូចពួកឥណ្ឌៀ ពួកចិន ពួកក្រេកសម័យថ្មី ពួកអ៊ីតាលី ហើយនឹងមនុស្សនៅចុងបុព៌ាប្រទេស នឹងសាសនអឺរុបខាងត្បូង ។ ការស្ងាត់តែងនាំមកនូវសេចក្ដីសុខស្រួលដល់មនុស្សជាតិ ហើយបញ្ចៀសនូវសេចក្ដីទុក្ខដែលកើតមកពីក្រុមពីគណៈ ។ នៅកណ្ដាលពួកក្រុមទាំងឡាយដែលមានគំនិតបែកពីគ្នាជាច្រើនគណៈ ដួងព្រលឹងយើងតែងញាប់ញ័រជាធម្មតា ដួងព្រលឹងវិលត្រឡប់ផ្កាប់ផ្ងារមិនឈប់-ឈរ មួយពាន់គំនិត តប់ប្រមល់យល់ឆ្វេង-ស្ដាំ ទាស់គ្នាហើយមានពួកជនខ្លះនៃសង្គមចិត្តអភិជ្ឈាហួសប្រមាណ ហើយជាអ្នកក្រីក្រតែងស៊ុឡិបពីគ្នាទៅវិញទៅមក ។ មានតែទីស្ងាត់ទេ ដែលអាចកំចាត់បង់នូវគំនិតអកុសលធ្វើដួងព្រលឹងឲ្យថ្លាបាន ។ ដួងចិត្តនេះវិលត្រឡប់ជាចិត្តថ្មី ហើយមានពណ៌រស្មីដូចដើម ។ ឧបមាដូចវារីជ្រៅដ៏ល្អក់ហូរកាត់ទីវាល ធ្លាក់ចុះ

កូនត្រពាំងមួយឆ្ងាយពីផ្ទះទឹក ទឹកនោះមានកក់ធ្លាក់ទៅក្រោម ត្រឡប់ជាទឹកថ្លាដូចដើមផ្ទះមុខបាន ពាំងស្រមោលព្រៃនៅមាត់ត្រពាំងទាំងប៉ុន្មានមើលឃើញទាំងអស់ ៗ មិនតែប៉ុណ្ណោះសោត សុញ្ញដ្ឋានរៀបចំកាយខាងក្រៅឲ្យសមរម្យនឹងដួងចិត្តខាងក្នុងផង ៗ គឺកូនពួកអ្នកស្វែងទីស្ងាត់ហ្នឹង ហើយដែលគេឃើញមានមនុស្សរុញការងារ ពេលឆ្ងាយពីខ្លួនជាច្រើន ដូចពួកព្រាហ្មណ៍ក្នុងប្រទេសឥណ្ឌជាឧទាហរណ៍ ៗ នៅទីបំផុតខ្ញុំយល់ថា ការងារសំខាន់ណាស់ខាងនាំមកនូវសេចក្ដីសុខស្រួលក្នុងលោកមែន តែបើតាមយល់ថែមទៀត មើលទៅមិនងាយនឹងសោយសេចក្ដីរីករាយកើតឡើងពីការងារបានពិតទេឡើយ ទោះបីតាំងចិត្តដូចម្ដេចក៏ដោយ ឬមួយទៀងកិរិយាមារយាទទៅលើច្បាប់យ៉ាងមិនកំរើកក៏ដោយ បើចិត្តខាងក្នុងមិនស្ងប់ស្ងាត់សោះបណ្ដោយឲ្យការយល់ទៅក្រៅ នឹងឲ្យការយល់របស់អ្នកដទៃមកលុកលុយខាងក្នុង ៗ ខ្ញុំមិនយល់ដោយដាច់ខាតថា មនុស្សត្រូវតែរស់នៅក្នុងទីស្ងាត់តែម្នាក់ឯងឡើយ: មនុស្សកើតមកសម្រាប់កិច្ចការទាំងឡាយ ដ្បិតព្រះជាម្ចាស់បង្កើតឲ្យយើងមានអាយតនៈគ្រប់គ្រាន់សមគួរដល់វត្ថុដែលមាននៅលើផែនដី ដូចជាជើងគូនឹងដី សួតគូនឹងអាកាស ភ្នែកគូនឹងពន្លឺ មិនចាំបាច់យើងពឹងការនៃទ្វារណាឲ្យមកជួយ ហើយបង្កើតចិត្តមួយជាអាយតនៈទីមួយជាមេលើជីវិតទាំងមូល ៗ

មនុស្សកើតឡើងសម្រាប់យើងប្រើ នឹងសម្រាប់ធ្វើបាបយើងផង ដូច្នេះបានជាខ្ញុំសុខចិត្តនៅតែឯងឆ្ងាយពីមនុស្សទាំងឡាយនោះ ។ ខ្ញុំបានត្រាច់ចរក្នុងប្រទេសអឺរ៉ុបអស់សឹងតែពាក់កណ្ដាល ប្រទេសអាមេរិកខ្លះ ប្រទេសអាហ្វ្រិកខ្លះ រួចហើយបានខ្ញុំមកជាតសសរ នៅក្នុងកោះនេះដែលមិនសូវមានមនុស្ស មានធាតុអាកាសស្រួលហើយស្អាតផង ។ ខ្ទមដែលខ្ញុំសង់នៅក្នុងព្រៃ ក្បែរឈើមួយដើម មានចំការមួយកាប់ពនដោយដៃខ្ញុំ ស្ទឹងមួយហូតកាត់ចំពីមុខផ្ទះខ្ញុំ របស់ទាំងនេះល្មមសមគួរដល់សេចក្ដីត្រូវការនឹងសេចក្ដីកែកាយរបស់ខ្ញុំ ។ មានគម្ពីរយ៉ាងល្អពីរ-បីសម្រាប់ប្រដៅចិត្តគំនិតឲ្យជាមនុស្សស្លូតត្រង់ត្រឹមត្រូវ បន្ថែមលើសេចក្ដីកែកាយខាងលើទៀត ។ សេចក្ដីសុខស្រួលខ្ញុំកើតមកពីយកមនុស្សទាំងឡាយដែលខ្ញុំរត់ចោលមកជាប្រមាណផង ដោយបានមើលគម្ពីរដែលរៀបរាប់ឲ្យឃើញនៅមុខ ពីរឿងតណ្ហាជាជមិនាំមនុស្សឲ្យលំបាករងទុក្ខវេទនាផងដល់ខ្ញុំយកពាក្យស្មាអ្នកទាំងឡាយនោះមកធៀបនឹងពាក្យស្មាខ្ញុំ ឃើញថាសេចក្ដីសុខស្រួលរបស់ខ្ញុំផ្ទុយពីសេចក្ដីសុខនៃជនទាំងនោះ ។ ខ្លួនខ្ញុំប្រៀបដូចមនុស្សលង់ទឹកទើបនឹងប្រាប់បានដុំថ្មជាទីពឹងនឹង ខ្ញុំក្រឡេកពីកន្លែងខ្ញុំទៅឃើញព្យុះសង្ឃរា កំពុងតែបោកបក់នូវមនុស្សសំណល់ញាក់ទទើកក្នុងលោក ។ សូរសន្ធឹកព្យុះពីចម្ងាយ រឹងរិតតែធ្វើវិសម្រាកនៃខ្ញុំឲ្យពេញជាទេគុណឡើង ។ (មានត)

# សកម្មភាព

## នៃក្រុមជំនុំទំនៀមទម្លាប់ស្រុកខ្មែរ

ចាប – ពិន ថ្លែងដាក់វិទ្យុប្រទេសកម្ពុជាពីថ្ងៃទី ១៥–១២–៥២

## ផ្សាយចេញពីពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

---

ក្នុងវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ មានក្រុមមួយ ជាក្រុមរក្សាគោលចារិកយ៉ាងសំខាន់របស់ប្រទេសកម្ពុជា គឺក្រុមជំនុំទំនៀមទម្លាប់ស្រុកខ្មែរដែលនឹងបរិយាយជូនដូចតទៅនេះ :–

ទំនៀមទម្លាប់ ជាលក្ខណៈសំខាន់មួយយ៉ាងរបស់មនុស្សជាតិ ក្នុងសង្គមក្នុងប្រទេស ដែលគ្រប់ប្រទេសក្នុងសកលលោកសព្វថ្ងៃនេះ គេកាន់តែត្រូវការចេះដឹងជាច្រើន នឹងគេត្រូវការរក្សាទុក មិនបំភ្លេចចោលទេ ព្រោះគេយល់ថាបើទំនៀមទម្លាប់របស់ជាតិគេសាបសូន្យ ជាតិគេក៏សាបរលាបមិនអាចគង់វង្សនៅបាន ។

ប្រទេសកម្ពុជាយើង ពិតមែនតែបានកាន់តាមអារ្យធម៌របស់ប្រទេសឥណ្ឌាជាច្រើន តែគង់មានរបៀបជាច្រើន ដែលជារបស់ខ្មែរសុទ្ធពិតៗ ហើយជារបៀបចាស់ ដែលខ្មែរយើងធ្លាប់បានប្រព្រឹត្តជាច្រើនសតវត្សមកហើយ, ប៉ុន្តែទោះបីខ្មែរយើងមានអារ្យធម៌ចាស់ដែលគេចង់ចាំពិតប្រាកដជារបស់ខ្លួនយ៉ាងណាក្តី ក៏នានាប្រទេសគេបានស្គាល់ខ្មែរយើងតិចប្រទេសនៅឡើយ, ទាំងនេះមិនពីព្រោះហេតុអ្វី គឺពីព្រោះហេតុអារ្យធម៌ខ្មែរយើងមិនទាន់បានផ្សាយទៅឲ្យគេស្គាល់ ។

ហេតុនេះ បានជាព្រះរាជរដ្ឋាភិបាលបានបង្កើតឲ្យមានក្រុមជំនុំមួយទៀតហៅថា "ក្រុមជំនុំទំនៀមទម្លាប់ស្រុកខ្មែរ" ដោយព្រះរាជប្រកាសលេខ ១២ ចុះថ្ងៃ ២៥ ១-៣៤ ។ មុខងាររបស់ក្រុមជំនុំនេះ មិនគ្រាន់តែបង្ហាញប្រពៃណីខ្មែរឲ្យជនបរទេសស្គាល់ប៉ុណ្ណោះទេ គឺមានភារៈខាងស្រាវជ្រាវរកក្រាំងសៀវភៅក្បួនខ្នាតដែលស្តីអំពីទំនៀមទម្លាប់ខ្មែរទៀតផង ព្រមទាំងដំកល់ទុកនូវឯកសារដែលទាក់ទងដោយទំនៀមទម្លាប់ខ្មែរ, រៀបរៀងបោះពុម្ពផ្សាយនូវឯកសាររឿងដែលបង្ហាញឲ្យឃើញផលប្រយោជន៍នៃការដែលបានពិភាក្សាអំពីប្រជាជនទាំងឡាយ នឹងបោះពុម្ពផ្សាយនូវទំនៀមទម្លាប់នានា មានព្រះរាជពិធីទ្វាទសមាសជាដើម ដើម្បីរក្សាទុកមិឲ្យបាត់អារ្យធម៌បុរាណរបស់ខ្មែរ ដែលច្រើនតែបាត់ឬក្រុបទៅទៀត ដើម្បីឲ្យបណ្តាជនជាតិខ្មែរយើង ឬនានាជាតិដែលចង់ចេះដឹងអារ្យធម៌របស់ខ្មែរយើង ដែលមកស្រាវជ្រាវរកនៅក្នុងទូទុកឯកសាររបស់ក្រុមជំនុំនេះឲ្យបានឃើញដោយងាយ នឹងឲ្យបានឃើញថាខ្មែរយើងបានកតត្រាអារ្យធម៌របស់ប្រទេសជាតិ តាំងពីបុរាណមកមិនមែនបំភ្លេចចោលទេ ។

ប្រពៃណីខ្មែរដែលក្រុមជំនុំទំនៀមទម្លាប់ត្រូវការស្រាវជ្រាវរកនោះ មានដល់៩៩មុខ មានថតទូសម្រាប់ដាក់ឯកសារដល់ទៅ ៩៩ ថត ដូចបានរាយឈ្មោះខ្លះដោយសង្ខេប គឺ:

ត្រុដិសង្ក្រាន្ត, ចូលឆ្នាំថ្មី, លើកកសី, ពេលា, ហោរាសាស្ត្រ, វេជ្ជ, ពិសាខបូជា, មាឃបូជា, ចូលវស្សា, ចេញវស្សា, ភ្ជុំបិណ្ឌ, កឋិន, ផ្កា, បញ្ចុះសីមា, បំបួសនាគ, សំពះព្រះខែ, លយប្រទីប, អកអំបុក, អុំទូក, អាពាហ៍ពិពាហមង្គល, ល្បែង, របាំ, មហោស្រព, ក្បួនព្យាបាលសឹក, វិធីសមយុទ្ធ (អាវុធគ្រឿង), ប្រវត្តិសាស្ត្រ, ភូមិសាស្ត្រ. ពង្សាវតារ ទំនៀមទំនៀមផ្សេងៗ ជាដើម ។ល។

ទំនៀមទម្លាប់ ដូចរាប់ឈ្មោះខ្លះមកនេះហើយ ដែលក្រុមជំនុំទំនៀមទម្លាប់ខ្មែរ ត្រូវការកត់ត្រាស្រាវជ្រាវប៉ៃមប្រមូលរកទីងរក្សាទុកឲ្យគង់នៅតទៅ ។

ឯដំណើរការស្រាវជ្រាវរកនោះមានរបៀបដូច្នេះ គឺ

១ - ចាត់ការស៊ើបសួរយកការកត់ត្រា នូវទំនៀមទម្លាប់ផ្សេងៗ នៅវេលាដែលប្រជាជនក្នុងសង្គមធ្វើពិធីផ្សេងៗ ដែលទាក់ទងដោយទំនៀមទម្លាប់ខ្មែរ;

២ - ចាត់ការបម្រុងឯកសាររឿងទំនៀមទម្លាប់ តាមសាស្ត្រាក្រាំងសៀវភៅក្បួនខ្នាតផ្សេងៗ ដែលខ្ញុំមកអំពីគ្រហស្ថបុព្វជិតនៅភូមិស្រុក ទីវត្តអារាមនានា ;

៣ ចាត់ការស៊ើបសួរយកការរឿងទំនៀមទម្លាប់អំពីពួកសមាជិកឆ្លើយឆ្លងនៅក្នុងស្រុក - ខេត្តនានា ដែលក្រុមជំនុំបានតាំងប្រចាំការ

សម្រាប់សាកសួរ ដោយបានឲ្យសមាជិកឆ្លើយឆ្លងទាំងនោះសរសេរឯកសារឲ្យការមកជារឿយៗ;

៤ – ចាត់ការប្រឡងប្រជែង រង្វាន់បេក្ខជនដែលស្ម័គ្រចិត្តប្រឡង រាល់ឆមាសនីមួយ ៗ គឺ ៦ ខែប្រឡងម្តងរៀងរាល់ឆ្នាំ ដើម្បីឲ្យបេក្ខជនទាំងនោះជូនឯកសាររឿងទំនៀមទម្លាប់ខ្មែរ តាមដែលក្រុមជំនុំត្រូវការចំពោះរឿងណាដែលមិនទាន់បានបរិបូណ៌ ។

ជនជាតិខ្មែរណាក៏សឹងតែចេះចាំទំនៀមទម្លាប់ខ្មែរដែរ, ប៉ុន្តែខ្លះចេះចាំច្រើនខ្លះតិច, វិញ្ញូជនទោះជាបព្វជិតក្តី គ្រហស្ថក្តី ដែលចេះចាំហើយនាំយកមកពណ៌នាពន្យល់ច្បាស់លាស់បាន, អាចធ្វើជាសមាជិកឆ្លើយឆ្លងរបស់ក្រុមជំនុំបានទាំងអស់ ។ ដោយក្រុមជំនុំយល់ឃើញថាវិញ្ញូជនដែលបានទទួលសរសេរតែងរឿងប្រពៃណីខ្មែរឲ្យការទៅក្រុមជំនុំនោះមានអំពល់ច្រើនក្នុងរឿងនេះ បានជារៀង ៦ ខែក្រុមជំនុំបានស្រង់យកម្តង នូវរឿងនានាដែលពួកសមាជិកឆ្លើយឆ្លងបានឲ្យការទៅនោះមកប្រជុំពិនិត្យហើយបានជូនរង្វាន់ជាប្រាក់តាមបំណាច់ ដែលសមាជិកឆ្លើយឆ្លងនោះៗ បានខំធ្វើដោយនឿយហត់ ។

ពួកសមាជិកឆ្លើយឆ្លងដែលបានឲ្យការទៅក្រុមជំនុំនោះ នឹងបានឃើញឈ្មោះរបស់ខ្លួន នៅពេលដែលក្រុមជំនុំបានផ្សាយអំពីកិច្ចការ

របស់ក្រុមជំនុំ កុងសារពត៌មានកម្ពុជា, កុងទស្សនាវដ្ដីកម្ពុជសុរិយា ឬកុងសៀវភៅដែលក្រុមជំនុំរៀបរៀងអំពីអារ្យធម៌ខ្មែរ ។

ពួកបេក្ខជនដែលបានសរសេរឯកសារ ផ្ញើទៅប្រឡងប្រជែងនោះ ក្រុមជំនុំនឹងជូនរង្វាន់ក្រោយដែលបានជួបជុំពិនិត្យឃើញថា ឈ្មោះណា បានជាប់រៀងណាថ្នាក់ណាហើយ ព្រមទាំងបានប្រកាសលទ្ធផលនៃការប្រឡងនឹងឈ្មោះបេក្ខជនដែលប្រឡងជាប់នោះៗ ពល់លើកុងសារពត៌មានកម្ពុជា ឬកុងទស្សនាវដ្ដីកម្ពុជសុរិយារបស់ពុទ្ធសាសនបណ្ឌិត្យផង ។

កិច្ចការរបស់ក្រុមជំនុំនេះ មានការៈយ៉ាងធំត្រង់ការស្រាវជ្រាវរកក្រាំងសៀវភៅក្បួនខ្នាតនានាដែលស្ដីពីទំនៀមទម្លាប់ខ្មែរឲ្យបានច្រើនមុខ, មួយមុខៗឲ្យបានចំនួនច្រើន, ដើម្បីយកឯកសារមួយមុខៗដែលមានច្រើនបែបនោះមកប្រៀបធៀបផ្ទឹមផ្ទៀងគ្នាមើល ឲ្យដឹងថាត្រូវគ្នា ឬប្លែកគ្នាយ៉ាងណាខ្លះ ដល់ពេលដែលនឹងរៀបរៀងជាសៀវភៅបោះពុម្ពឡើងឲ្យបានមានគោលចារិកត្រឹមត្រូវល្អ ។

ឯការស្រាវជ្រាវដែលនឹងបានច្រើនមុខហើយកុងមួយមុខៗ ច្រើនបែបនោះលុះតែអស់លោកវិញ្ញូជនច្រើនរូបជួយឧបត្ថម្ភផង គឺឧបត្ថម្ភដោយសរសេរនូវឯកសាររឿងទំនៀមទម្លាប់ផ្សេងៗតាមចេះចាំឬបានចម្លងតាមក្រាំងសៀវភៅក្បួនខ្នាតផ្សេងៗ ដែលមានតាមវត្តអារាមកុងភូមិស្រុក

ដោយដាក់ដើមកំណើតគឺឈ្មោះនិងទីលំនៅអ្នកម្ចាស់ក្បួន, ព្រមទាំងឈ្មោះនិងទីលំនៅអ្នកសរសេរចម្លងឯកសារ ឲ្យការទៅនោះយ៉ាងច្បាស់លាស់ ផ្ញើទៅឲ្យក្រុមជំនុំឲ្យបានច្រើន ៗ ក្រុមជំនុំសង្ឃឹមមាំលើអស់លោកវិញ្ញូជនទាំងឡាយទូទៅទាំងប្រទេសកម្ពុជាទាំងមូល, ដែលបានយកចិត្តទុកដាក់ក្នុងការនេះ ។

ដូច្នេះ, អស់លោកអ្នកជាវិញ្ញូជនទាំងឡាយ ទោះជាគ្រហស្ថក្តី ជាបព្វជិតក្តី ដែលបានចេះចាំនូវទំនៀមទម្លាប់ជាអារ្យធម៌ខ្មែរ, ហើយដែលមានប្រាថ្នានឹងរក្សាទុកឲ្យគង់នៅ ដើម្បីជាគោលបារិកនឹងជាព្រំដែនរបស់ខ្មែរតទៅ ; សូមជួយជ្រោមជ្រែងដោយការឧបត្ថម្ភ ៣ យ៉ាង គឺ

១ ) ដោយទទួលធ្វើជាសមាជិកឆ្លើយឆ្លងរបស់ក្រុមជំនុំទំនៀមទម្លាប់ ហើយសរសេរឯកសារផ្សេងៗ ដែលទាក់ទងដោយទំនៀមទម្លាប់ខ្មែរ តាមបញ្ជីរាយឈ្មោះថតទាំង ៩៩ ប្តុណាមួយដូចបានរៀបរាប់ពីខាងដើមមក ហើយនោះផ្ញើទៅឲ្យក្រុមជំនុំ;

២ ) ដោយទទួលធ្វើជាបេក្ខជនសរសេរឯកសាររឿងទំនៀមទម្លាប់ខ្មែរផ្សេងៗ ផ្ញើទៅប្រឡង តាមកាលបរិច្ឆេទដែលក្រុមជំនុំបើកឱកាសប្រឡងប្រជែង ដែលជូនដំណឹងតាមប្រកាសការប្រឡងរៀងរាល់ឆមាសតទៅ;

៣) ដោយមិនទទួលធ្វើជាសមាជិក ឬបុគ្គលទេ គ្រាន់តែសរសេរចម្លងក្បួនខ្នាតរៀងរាំទៀមទម្លាប់ផ្សេងៗ ផ្ញើទៅឲ្យក្រុមជំនុំ ឬឲ្យក្រុមជំនុំចំរើក្បួនខ្នាតរៀងរាំទៀមទម្លាប់ទៅចម្លង ។

បណ្ដាការឧបត្ថម្ភទាំង៣យ៉ាងនេះ លោកអ្នកវិញ្ញូជនណាមួយនោះជួយឧបត្ថម្ភបែបណាក្ដីក៏ឈ្មោះថា បានជួយជ្រោមជ្រែងកិច្ចការរបស់ក្រុមជំនុំទំនៀមទម្លាប់ស្រុកខ្មែរ ឲ្យបានរុងរឿងទាំងអស់, ហើយបានឈ្មោះថាជាអ្នកស្នេហាជាតិ ជួយឧបត្ថម្ភការធម៌របស់ប្រទេសជាតិឲ្យមានគោលចារិកល្អផង ថែមទាំងបានរង្វាន់ជាប្រាក់សមគួរតាមបំណាច់ដែលនឿយហត់ក្នុងការជួយឧបត្ថម្ភនោះផង ។

ក្រុមជំនុំសូមទទួលអំណរគុណយ៉ាងខ្ពស់ទុកជាមុនចំពោះអស់លោកអ្នកដែលបាន យកចិត្តទុកដាក់ជួយទំនុកបម្រុងកិច្ចការរបស់ក្រុមជំនុំនេះឲ្យបានចម្រើនជាតិយោភាព ។

សេចក្ដីបរិយាយអំពីសកម្មភាព នៃក្រុមជំនុំទំនៀមទម្លាប់ស្រុកខ្មែរនៅវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ អស់ត្រឹមប៉ុណ្ណេះ ។

តទៅខាងមុខ យើងនឹងបរិយាយអំពីសកម្មភាពនៃវិជ្ជាស្ថាននេះជាផ្នែកៗជូនលោកអ្នកតទៅទៀត ។

---

សន្ទិសិទព្រះពោធិវង្ស ហួត-តាត

ចាងហ្វាងសាលាបាលីជាន់ខ្ពស់ ជាប្រធាននៃគណៈប្រតិភូខ្មែរ

ថ្លែងអំពីសមាជសាកលលើកទី ២ នៃពុទ្ធសាសនា

នៅទីក្រុងតូក្យូ ( ប្រទេសជប៉ុន )

# ពុទ្ធសាសនបណ្ឌិត្យ

(តមក)

---

អាត្មាសំដែងមកនេះ មិនបានពណ៌នាឲ្យបានសព្វគ្រប់ទេ គ្រាន់តែពោលត្រួសៗ អំពីរឿងផ្សេងៗ មិនបានពោលពីផលិតកម្ម ទិដ្ឋភាពក្នុងប្រទេស, វាល, ភ្នំ, មាត់សមុទ្រ, ប្រពៃណីនិយម, ទំនៀមទម្លាប់, ពាណិជ្ជកម្ម, ឧស្សាហកម្ម, សង្គម, នយោបាយជាដើម ។ នៅទីក្រុងគេក្រឡេកទៅឃើញភ្នំភ្លើងមួយឈ្មោះហ្វូស៊ីយ៉ាម៉ា នៅកណ្ដាលកោះហុងដូ បញ្ចេញផ្សែងខ្មៅទៅលើអាកាស ។ បើតាមពិនិត្យសេដ្ឋកិច្ចឃើញមានស្រូវដាំក្នុងសួន ដោយយកចបរនាស់ដែកជ្រួយកាស់ដី គ្មានសត្វប្រើទេ ឃើញមានដាំដើមខ្ពៅ ស្រូវសាលី ពោត ។ ដើមតែមានដាំជាច្រើន, បានជាមានពិធីបរិភោគតែ ជាទំនៀមជាប់ពីបុរាណមក តែឲ្យសុខ តែឲ្យសេរីសួស្ដី តែឲ្យជយមង្គល ។ មានគេចិញ្ចឹមសត្វជាច្រើន មានចៀម, មាន់, គោ, សេះ, មានរបរចាប់ត្រី ។

ក្រៅពីនេះមានលោហធាតុផ្សេងៗ ដែក, ធ្យូងថ្ម, ប្រេងកាត, មាស, ប្រាក់, ស្ពាន់, ស្ពាន់ធ័រជាដើម ។ គេយកកំលាំងទឹកជ្រោះក្នុងគុហាភ្នំជាកំលាំងសម្រាប់បង្វិលគ្រឿងចក្រភ្លើងអគ្គិសនី ។ មានការឧស្សាហកម្មខាងគ្រួសារ ធានប៉ូសឺឡែន, ធានដី, ការប៉ាក់ជរសំពត់ព្រែ, កន្ទេល, ក្រដាស, របស់សម្រាប់ក្មេងលេង, តុ, ទូ, កៅអីជាដើម ។

មុននឹងបញ្ចប់សេចក្តីនេះ អាត្មាសូមជំរាបសាធុសប្បុរសទាំងឡាយថា អាត្មាចេញពីវត្តដែលសំណាក់ដោយមានរថយន្តទៅទទួល, កាលទៅដល់ទីកន្លែងមួយក៏ចុះពីរថយន្ត ស្រាប់តែឃើញក្មេងអាយុ ៦-៧ ឆ្នាំ ឈរតម្រៀបគ្នាប្រហែល ២-០០០ នាក់ គំនាប់អាត្មាជាកិត្តិយស ។ អាត្មាបានសួរថា: ក្មេងនេះមកធ្វើអ្វី? គេប្រាប់អាត្មាថា: "ក្មេងទាំងនេះ ស្ថិតនៅក្នុងពួកសមាគម ហៅថា "សមាគមអប់រំក្មេងខាងព្រះពុទ្ធសាសនា ឬសមាគមយុវពុទ្ធសាសនា" ។ សមាគមនេះមានវត្ថុបំណង ត្រង់ការអប់រំក្មេងនេះឲ្យរៀនសូត្រខាងព្រះពុទ្ធសាសនា ព្រោះប្រទេសជប៉ុនខ្លាចក្រែងវិនាសព្រះពុទ្ធសាសនាទៅអនាគត ដោយហេតុណាមួយ, គេភ័យនឹងព្រះពុទ្ធសាសនា, គេរិះរកមធ្យោបាយផ្សេងៗ ដើម្បីឲ្យព្រះពុទ្ធ-សាសនាគង់ទ្រង់តទៅ ។ សមាគមនេះ មិនមែនមានត្រឹមតែប្រទេសជប៉ុនទេ, ប្រទេសឥណ្ឌា, ភូមា, សៀម គេក៏មានហើយ, នៅតែប្រទេសកម្ពុជាមិនទាន់មាននៅឡើយ បានជាអាត្មាមកដល់ព្រះរាជធានីភ្នំពេញ

ចូលទៅថ្វាយព្រះពរស្មើព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង អំពីរឿង ស្ថាប័នានូវសមាគមបែបនេះ នៅប្រទេសកម្ពុជា ។ ទ្រង់សព្វព្រះរាជហឫទ័យបង្កើតឲ្យមានសមាគមនេះដែរ ។

នៅទីនេះ អាត្មាមិនបានពោលអំពីផ្សេងគមនាគមន៍, ថ្នល់, អយស្ម័យយាន, សមុទ្រជាដើម គ្រាន់តែពោលអំពីពុទ្ធសាសនានៅប្រទេសជប៉ុន នឹងសាសនាស៊ីនតូ ។

ព្រះពុទ្ធសាសនានៅប្រទេសជប៉ុនមកពីប្រទេសចិន ផ្សាយតាមប្រទេសកូរេតាំងពីសតវត្សរ៍ទី ៦ គ. ស. ។ ការស្ថាបនាព្រះពុទ្ធសាសនាដំបូងនៅប្រទេសជប៉ុន បានជួបប្រទះនឹងការជំទាស់របស់ជនជាតិក្នុងស្រុក, ទៅជាឧបសគ្គមួយធំ តែការផ្សាយព្រះពុទ្ធសាសនា ក៏ដើរជាប់ទៅក្នុងសន្តានចិត្តប្រជាពលរដ្ឋ មានវត្តជាច្រើនគេសាងនៅទីក្រុងនរ, គីយ៉ូតូ, កាម៉ាគុរ៉ា ជាដើម ។ មានគណៈជាច្រើន ទាំងអស់ ១២ គណៈ គឺគណៈស៊ីងតុងកើតឡើងដោយជនកបុរសនាមគូបូដៃស៊ី ពីសតវត្សរ៍ទី ៨ គ ស, គណៈហូណែក សតវត្សរ៍ទី ១២ ។ ក្នុងពេលនោះមានគណៈមួយទៀត កើតឡើងដោយមានលោកនីឈីរែនជាជនកបុរស ព្រមទាំងគណៈផ្សេងទៀត ។ អាត្មាមិនបានពណ៌នាព្រះពុទ្ធសាសនានៅប្រទេសជប៉ុន ឲ្យជាវិត្ថារពិស្ដារទេ លំដាប់តអំពីនេះនឹងពណ៌នាសាសនាស៊ីនតូហើយនឹងបញ្ចប់ ។

ពាក្យជប៉ុនថា ស៊ីនតូ ប្រែថា "ផ្លូវព្រះអាទិទេព" ។ សាសនានេះប្រហែលជាសាសនាក្លាយពីសាសនា "តៅ" ដែលបណ្ឌិតឡៅស៊ីនៅប្រទេសចិនបានស្ថាបនាពីមុនមក ព្រោះថា "តៅ" នេះ ក៏ប្រែថា "ផ្លូវ" ដូចគ្នានឹងភាសាជប៉ុនថាស៊ីនតូ ។ សាសនានេះពណ៌នាឲ្យវែងឆ្ងាយទូលាយក៏បាន តែពេលវេលានេះខ្លីណាស់ គ្រាន់តែជំរាបថាសាសនានេះមានយកសត្វតិរច្ឆានមកសូនឲ្យជារូប ថាជារូបដូនជីតា ហើយក៏នាំគ្នាគោរពបូជា ព្រមទាំងប្រតិស្ឋាននូវពលភាពធម្មជាតិទៅជាទេវតា, មានបុញ្ញានុភាពចំពោះសត្វតិរច្ឆាន, គេបានឃើញនៅភូមិភាគប្រទេសជប៉ុនខាងជើងមានធ្វើ "ពិធីបុណ្យសត្វខ្លាឃ្មុំ" ដែលគេទុកជាជីតា ហើយក៏នមស្សការថ្វាយបង្គំ ។ មានទីកន្លែងខ្លះ គេកំតាមប្រពៃណីនិយម ដើម្បីធ្វើបដិសណ្ឋារៈចំពោះទេវតា ដែលគេគោរពកប់អាន ។ មានតាមភូមិខ្លះ មានធ្វើពិធីបុណ្យខាងក្សេត្រាធិការ សែនទេវធីតាទុកបំរុងស្រូវជាដើម ។ មានទីខ្លះ មានធ្វើពិធីលាងវត្ថុឲ្យផុតពីចង្រៃ ឲ្យទៅជារបស់មានសិរីសួស្តីទៅវិញ ។ សាសនានេះមានសរសេរទុកនៅក្នុងសៀវភៅពិសិដ្ឋគឺ កូជីគី ១ និហុងគី ១ តាំងពីសតវត្សរ៍ទី ៨ គ.ស. ។ សៀវភៅនិទានថា: "ព្រះអាទិទេព (អ៊ីសានគី) នឹងព្រះអាទិទេវី "អ៊ីសាណាមី" បានរួមសមរសនឹងគ្នាកើតជាកោះ, ភ្នំ, ទឹក, ផ្កា, ព្រមទាំងទេវតាទេវធីតាផ្សេងៗ រូប

តមកនាង:ទេវធីតានៃព្រះសុរ្យា នាម "អាម៉ាតេរស៊ឹ" នឹងបងប្រុសនាម "ស៊ឹសាណូ" ។ ការឈ្លោះទាស់គ្នានៃទេវធីតានឹងបងប្រុស នាំឲ្យទេវធីតាប្រគល់ឲ្យព្រះរាជបុត្រត្រូតត្រាប្រទេសរាល់ត្រែង គឺប្រទេសជប៉ុននេះឯង; ព្រះនាងបានធ្វើព្រះរាជអំណោយចំពោះព្រះរាជបុត្រនូវកញ្ចក់មួយ គឺជាព្រះរាជកេតនភណ្ឌជាពិសិដ្ឋ ចំពោះព្រះរាជកេតនភណ្ឌទាំងបី តាំងពីនោះក៏ស្ថាបនានូវសន្តតិវង្សព្រះអធិរាជប្រទេសជប៉ុន ។

នៅគ.ស. ១៨៦៨ រដ្ឋាភិបាលព្រះបាទមៃជី បានព្យាយាមប្រកាសសាសនាស៊ីងតូ ជាសាសនារបស់រដ្ឋ ឯកត្យានុភាពនៃព្រះពុទ្ធសាសនាក្នុងពេលនោះមិនអាចធ្វើបាន ។ ព្រះវិហារធំជាងគេនាមថា: "អ៊ីសេ" គ្មានរូបអ្វីជាទីគោរព ធ្វើពីឈើ គ្មានរបនាដោយក្បាច់ចំឡាក់អ្វីសោះឡើយ ខុសគ្នាពីព្រះវិហារព្រះពុទ្ធសាសនា ដែលតុបតែងដោយក្បាច់សិល្ប: ព្រមទាំងតាំងព្រះពុទ្ធរូប ជាទីគោរពជាច្រើន ។

នៅទីនេះ មិនបានពណ៌នាអំពីប្រវត្តិសាស្ត្រប្រទេសជប៉ុន ព្រមទាំងគ្រិស្តសាសនា ។

អាត្មាពណ៌នាសេចក្តីខាងលើនេះ គឺពោលសារុបទាំងសន្ធិសេទនៅវត្តព្រះកែវមរកតនឹងវត្តលង្កា ត្រង់កន្លែងដែលចាំ មានកន្លែងខ្លះមិនបានចាំមិនបានយកមកអធិប្បាយទេ ។

(មានត)

# សុន្ទរកថា

## លោកដុកទ័រគុណបលៈបិយសេនៈម៉ាល៉ាលៈសេកេរៈ

ជាប្រធានពុទ្ធិកសមាគមពិភពលោក ថ្លែងក្នុងពេលសមាជសាកល
លើកទី ២ នៃពុទ្ធសាសនា នៅក្រុងតូក្យូ (ប្រទេសជប៉ុន)
(តូក្យូ ២៥ កញ្ញា, ១៣ តុលា ១៩៥២)

ពុទ្ធសាសនបណ្ឌិត្យ

---

នមោ ពុទ្ធាយ

ព្រះភិក្ខុសង្ឃទាំងឡាយ ! ញាតិទាំងបុរស-ស្ត្រីទាំងឡាយ !
សហជីវិននៃបុព្វហេតុពិសិដ្ឋពុទ្ធសាសនាទាំងឡាយ !
កល្យាណមិត្តទាំងអស់ !

ខ្ញុំសូមនមស្ការ ក្នុងនាមនៃពុទ្ធិកសមាគមពិភពលោក ចំពោះព្រះសម្មាសម្ពុទ្ធ ដែលមានព្រះករុណាទិគុណ, ពុទ្ធោវាទ គឺព្រះធម៌និងព្រះសង្ឃ ដែលជាអ្នករក្សាកេរ្តិ៍មរតកព្រះបរមគ្រូជាម្ចាស់ ។

យើងសូមថ្លែងនូវអំណរជាយ៉ាងក្រៃលែង ដោយយើងទាំងអស់គ្នាបានមកជួបជុំនៅដី "បុប្ផាសិរិសេ ប្រទេសជប៉ុន" នេះ ដែលមានកិច្ចការដ៏ប្រសើរតាំងពីបុរាណកាលមក ហើយមនោសញ្ចេតនាជាបឋមរបស់យើងគឺការសំដែងនូវកតញ្ញូដ៏ពន្លឹក ចំពោះក្រុមប្រឹក្សាពុទ្ធសាសនា នៃប្រទេសជប៉ុន ដែលជាអ្នកស្នើចំពោះការផ្តើមមហាសន្និបាតនេះ ដែលមាន

គណៈប្រតិភូទាំងបុរស-ស្ត្រី ។ គណៈប្រតិភូនេះ មានសញ្ជាតិផ្សេងៗគ្នា អញ្ជើញមកពីប្រទេសប្លែកៗគ្នា មានខ្លះចម្ងាយជាច្រើនពាន់ម៉ែល៍ មករួបរួមនឹងយើង ដើម្បីវិនិច្ឆ័យអំពីរឿងនេះ ព្រមទាំងទទួលសេចក្តីសប្បាយ នឹងការផ្លាស់ប្តូរយោបល់គ្នាទៅវិញទៅមក ។ យើងសូមថ្លែងនូវសេចក្តីអរគុណ ជាយ៉ាងក្រៃលែងចំពោះលោកដុកទ័រម៉ាកូតូណា-កៃ ប្រធាននៃក្រុមប្រឹក្សាពុទ្ធសាសនា នៅប្រទេសជប៉ុន ដែលមានល្បីល្បាញជាអ្នកវិញ្ញូបុគ្គលនៅក្នុងពិភពលោក ។

ចំពោះក្នុងអ្នកដំណើរសាម័ញ្ញ ប្រទេសជប៉ុន គេបានចុះនាមថា ប្រទេសបុប្ផាគ្រិសង់ ថែមទាំងព្រះសុរិយោរះ ចំណែកយើង ប្រទេសជប៉ុន ជាប្រទេសមានទិដ្ឋភាព ដូចខាងលើ តែប្រទេសនេះជាប្រទេសដែលសមាគម នឹងព្រះសម្មាសម្ពុទ្ធអមិទៈ ហើយនឹងព្រះពុទ្ធក្វាន់-យិន ជាប្រទេសគិរីហ្វូងស៊ីយ៉ាម៉ាពិសិដ្ឋ ដែលអ្នកកវីចំណានម្នាក់ ឈ្មោះម្យាមួន បានយកទៅនិពន្ធជាយ៉ាងពីរោះ ជាព្រះរាជអាណាចក្រនរៈ នឹងកមកុរៈ ជាដីកិរិហាយ ប្តុបុកវត្តដែលមាននាមថា ហូរ្យុជី ហើយនឹងក្យូយ៉ា-សានជាស្ថានទីពិសិដ្ឋស្រមាប់បូជនិយេសន៍ ចំពោះពុទ្ធសាសនិកជនពិភពលោក ជាប្រទេសនៃរឿងរបាំណូ ហើយនឹងស្នាដៃសិល្បកម្ម ព្រមទាំងអក្សរសាស្ត្រខាងបព្វជិត នឹងគ្រហស្ថ ជាមាតុភូមិនៃលោកស្វគ្គ ហើយនឹងរីគិយូ ព្រមទាំងប្រទេសដែលគេនិយមការបូជានូវកែ

ជាបដិមារូបបញ្ជាក់ឲ្យឃើញ អំពីគុណសម្បត្តិសំខាន់ៗ ខាងពុទ្ធសាសនា មានការរៀបរយ និងការគោរព មានវិសុទ្ធិចិត្ត និងការស្ងប់ស្ងាត់; បរិយោសានជាដីដែលពួកបណ្ឌិតកែទម្រង់សាសនា និងពួកសន្តបុរស ដូចជាសុគ្គត ភៃស្ហ៊ី. ដង់ស៊ីយូ-ដៃស្ហ៊ី, កូបូដៃស្ហ៊ី ជូនសេន សង់ដី. ហូណាង់ សិនរ៉ាន និងនិចិរេន ។

## ប្រទេសជប៉ុនកាន់ពុទ្ធសាសនា

ចំពោះពុទ្ធសាសនិកជន ប្រទេសជប៉ុនបានប្រមូល នូវលទ្ធផល ដែលកើតមកពីផែនការណ៍ជាច្រើន ។ ប្រជាជាតិនេះបានទទួលនូវការសក្ការៈ ដែលជាគុណទៃព្រះសម្មាសម្ពុទ្ធ ព្រមទាំងលំនាំរស់នៅតាមពុទ្ធានុញ្ញាត ។ កង់វេងជាច្រើនសតវត្សមកហើយ ការគមនាគមនៃព្រះពុទ្ធសាសនា និងប្រវត្តិនយោបាយនៃប្រទេសជប៉ុន កាន់តែជិតស្និទ្ធ ។ ព្រះពុទ្ធសាសនាទៅជាសាសនារបស់រដ្ឋជប៉ុន យើងអាចវិនិច្ឆ័យបាន នូវលទ្ធផលល្អប្រពៃក្រក់ក្នុងសម្ពន្ធកិច្ចនេះ ។ បឋម, ចរិតនិស្ស័យខាងបុរាណវត្ត ប្រកបដោយវីរភាពនៃប្រទេសជប៉ុនបានស្វែងរកឃើញនូវសភាពមួយ ជាសាមញ្ញលក្ខណៈ ហើយត្រង់ចំពោះសាសនាជាដំបូង គឺព្រះពុទ្ធសាសនានេះឯង ដែលបានឲ្យប្រាជ្ញានិងគំនិត ធ្វើឲ្យប្រជាកស្រួបញ្ចេញនូវមតិបានពេញលេញ, សាសនានេះធ្វើឲ្យប្រទេសជប៉ុន មានអារ្យធម៌ប្រកបដោយមនុស្សជាតិ និងមានសភាព

ស្ងួតស្រួលព្រមទាំងប្រាជ្ញា គឺគុណធម៌ទាំងពីរនៃករុណាបញ្ចូលទៅនឹងប្រាជ្ញា ដែលជាកូនសោស្រមាប់បង្ហាញ ឲ្យយល់ច្បាស់នូវលទ្ធិនៃព្រះសម្មាសម្ពុទ្ធ ។ សាសនាបេនាប្រទេសជប៉ុន ឲ្យមានការបដិវត្តន៍មួយចំពោះទឹកចិត្ត អក្សរសាស្ត្រ នឹងសិល្បសាស្ត្រ ។ ប្រវត្តិសាស្ត្របានបង្ហាញ នូវចរិយាជនជាតិជប៉ុន គឺរីកសម្បើមព្រមទាំងធ្វើទឹកមុខឲ្យស្នេហាពេញទាំងពីរយ៉ាង ដែលកើតឡើងពីកំសួលពុទ្ធសាសនាផ្សាយចូលជ្រួតជ្រាបទៅក្នុងចរិតនិស្ស័យជនជាតិនេះ ។ កំសួលនេះ ធ្វើឲ្យជនជាតិជប៉ុនមានចិត្តមេត្តាចំពោះសត្វតិរច្ឆាន ពិតមែនតែជនជាតិខ្លះមិនបានបរិភោគផ្លែឬមើមឈើ ។ ការជាប់ជំពាក់នៃសិល្បកម្មជប៉ុន ចំពោះព្រះពុទ្ធសាសនានេះ ហើយមានសារៈសំខាន់ ព្រោះថាមកពីព្រះពុទ្ធសាសនា បានជាវិចិត្រសិល្បៈក្បាច់រចនា, ក្បួនតុបតែងគេហដ្ឋាន, ការឆ្លាក់ដោយស្ពាន់សំណ; ការបោះពុម្ពនិងអក្សរជាតិ បានចូលមកប្រតិស្ឋាននៅប្រទេសជប៉ុន ។ គឺមកពីសាលាវត្តដែលមានចំពោះភូមិនិមួយៗ ដែលបានទទួលការសិក្សាយកមកអប់រំពួកប្រជារាស្ត្រគ្រប់សង្គម ។ ពិតមែនតែពួកទាហានត្រូវទុកឲ្យនៅក្រៅកំសួលនេះ ពួកនេះក៏ត្រូវការបំពេញវិទ្យាក្រៅពីតិកនិក គឺវិទ្យាមានលំនាំទូទៅ ដោយយកព្រះសង្ឃមកបង្ហាត់បង្រៀនដែរ ។

ព្រោះហេតុដូច្នោះ បានជាកំសួលព្រះពុទ្ធសាសនានៅប្រទេសជប៉ុន មានសភាពសម្បើមអស្ចារ្យ មិនត្រឹមតែផែនការណ៍ខាងសាសនាទេ

ថែមទាំងមានខាងនយោបាយ ការសិក្សានិងសិល្បសាស្ត្រ ។ ព្រះពុទ្ធ-សាសនាបានអប់រំ ដុសខាត់ធ្វើឲ្យមានទម្រង់ល្អឡើង នៃចរិតនិស្ស័យជនជាតិជប៉ុនព្រមទាំងឧបត្ថម្ភត្រង់ការពង្រីកនូវប្រាជ្ញាប្រជាជាតិ ឲ្យដុះដាលច្រើនឡើង ។ សភាពដ៏ឧត្តមនៃព្រះពុទ្ធសាសនានេះ កើតឡើងក្នុងសម័យ ដែលប្រទេសជប៉ុនបានបំពេញកិច្ចការ ឲ្យបានពិតប្រាកដ តែតមកក៏ចុះអន់ទន់ទាបទៅវិញ ដោយគេទុកព្រះពុទ្ធសាសនាជាថ្នាក់ទីពីរ ហើយមិនសូវគោរពប្រតិបត្តិ ហើយដោយពួកអ្នកណែនាំប្រជាជាតិពេញចិត្តខាងគតិ ជាសម្ភារៈប្រយោជន៍ ។ ពិតមែនតែប្រទេសនេះនៅមានភោគទ្រព្យប្រកបដោយសម្ភារៈ តែវត្ថុទាំងនេះបានមកពីការស្វែងទៅខាងផ្លូវខុស ។ ពេលទុក្ខលំបាកនេះ របនាចរិតនិស្ស័យនៃប្រជា-ជាតិ ហើយដឹកនាំប្រជាជាតិនេះឲ្យយល់ច្បាស់នូវតម្លៃជាតិ ។ ក្រោយព្យុះសង្គ្រាម, ការទារុណកម្ម នៃមហាសង្គ្រាម និងផលដ៏អាក្រក់, មហាប្រទេសជប៉ុន បានមានជីវិតរស់ចេញពីផេះ (ស្លាប់ហើយរស់ឡើងវិញ) ការសំគាល់ចំពោះកិច្ចនេះ មានលំនាំស្រួលហើយចរិតនិស្ស័យដែលធ្លាក់ទៅក្នុងទុក្ខលំបាកនៃប្រជាជាតិនោះ បានបញ្ចេញនូវរស្មីក្នុងពេលសន្តិភាពនេះ ។ ជីវភាពដែលរស់នៅជាថ្មីនេះ បម្រុងនឹងយកទៅអនុវត្តន៍ ចំពោះការស្វែងនូវឧត្តមគតិទៅតាមពុទ្ធោវាទនេះ ជាពរមួយដ៏ប្រសើរ ដែលយើងមកជួបជុំគ្នា ជាគណៈប្រតិភូនៃពុទ្ធបរិស័ទ

កន្ទ្វីបទាំងបួននៃសាកលលោក យើងសូមគោរពចំពោះប្រទេសជប៉ុន ដែលទើបចាប់បដិសន្ធិថ្មី ហើយសូមជូនទៅប្រជារាស្ត្រ នូវសមានចិត្ត ដ៏ថ្លៃថ្លា និងសហការដ៏ប្រសើររបស់យើង ។

## ពុទ្ធិកសមាគមពិភពលោក

ប្រហែលជាងពីឆ្នាំមកហើយ គឺនៅក្នុងខែឧសភា ១៩៥០ ដែល ពុទ្ធិកសមាគមពិភពលោកបានស្ថាបនា នៅកោះសីឡង់នៅបន្ទប់ធំនៃ មហាវិហារ ព្រះបទ្មកែវឯទីក្រុងកន្ទី ជាអតីតព្រះរាជធានីនៅកោះ លង្កា ។ ការផ្តើមបង្កើតនៅសមាគមនេះ មកពីមានបំណងដ៏ជ្រាល ជ្រៅត្រង់ប្រមូលព្រមទាំងរួបរួមនូវពួកពុទ្ធបរិស័ទនៃពិភពលោក ដោយ មានវត្ថុបំណងជាធំត្រង់ការរស់នៅ ទៅតាមពុទ្ធោវាទ ហើយនិងផ្សាយ នូវលទ្ធិដ៏ប្រសើរនេះឲ្យជ្រួតជ្រាបគ្រប់ៗ គ្នា ដើម្បីឲ្យសន្តិភាព និង សុភមង្គលស្ថិតនៅពាសពេញផែនដីទាំងអស់ ។ ពូជដែលដុះឡើងមាន បំណង ឲ្យប្រែទៅជារុក្ខជាតិ មានពលភាពដ៏អស្ចារ្យ ។ ពូជនេះ ស្រប់ស្រាប ដោយធន្ធៈដ៏ខ្លាំងក្លានិងសមានចិត្តបរិភោគនូវវិរិយភាពនិង សច្ចធម៌ជាអាហារដ៏វិសេសវិសាល ហើយបក់ដោយវាយោស្រួលត្រជាក់ ដ៏ចិត្តសន្តោស និងសម្មាទិដ្ឋិ អាចចំរើន រំយវឌ្ឍនាការឡើង រីកធំ ពេញមនុស្សធម៌ ដែលមានម្លប់ត្រូវឲ្យសុខកាយសប្បាយចិត្ត ។ សេចក្តី សង្ឃឹមហើយនិងវត្ថុបំណងរបស់យើងត្រូវស្ថិតនៅក្នុងទីនេះ សេចក្តី ព្យាយាមរបស់យើង គម្រង់ឆ្ពោះត្រង់ទៅក្នុងទីនោះ ។ (មានត)

# បញ្ជីរាយនាមចៅអធិការដែលតាំងថ្មី

## របស់ក្រសួងធម្មការ

(តមក)

---

សញ្ញាប័ត្រលេខ ៨៥៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ អ៊ួន-អុន នាមឆាយា គន្ធគោ កើតឆ្នាំរោង អាយុ ៧០ វស្សា ១០ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុកខេត្តដដែល ។

សញ្ញាប័ត្រលេខ ៨៥៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ញឹក ង៉ួន នាមឆាយា ង៉ួនសរោ កើតឆ្នាំមមី អាយុ ៣២ វស្សា ៩ ជាគ្រូសូត្រស្តាំវត្តកោះកែវមុនីឧត្តម ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៨៥៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ឈិម-សេក នាមឆាយា ទិលសរ កើតឆ្នាំខាល អាយុ ៦០ វស្សា ៤១ ជាគ្រូសូត្រស្តាំ វត្តពោធិវង្ស ឃុំជង់ឡូង ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៨៥៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ខែក-ប៉ៅ នាមឆាយា ចន្ទសរ កើតឆ្នាំម្សាញ់អាយុ ៤៥ វស្សា ២៦ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំស្រុក ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៨៥៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ មាស-ឃឹម នាមឆាយា សុវណ្ណគោ កើតឆ្នាំកុរ អាយុ ២៧ វស្សា ៨ ជាគ្រូសូត្រស្តាំ វត្តកោះធំ ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៨៥៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ មុំក-ហែម នាមឆាយា ព្រហ្មបញ្ញា កើតឆ្នាំមមី អាយុ ៥៦ វស្សា ៣៧ ជាចៅអធិការ វត្តពោធិសុទសរ្ស ឃុំ-ស្រុក ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៨៥៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ព្រំ-ប៊ុន នាមឆាយា ប៊ុនតេ្ករ កើតឆ្នាំជូត អាយុ ៣៨ វស្សា ១៨ ជាគ្រូសូត្រស្តាំ វត្ត-ឃុំ-ស្រុក-ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៨៦០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ប៉ាល់-ឈួន នាមឆាយា ទិលសរ កើតឆ្នាំជូត អាយុ ៣៤ វស្សា ១៦ ជាចៅអធិការវត្តពោធិ៍មានបុណ្យ ឃុំបាក់ទឹម ស្រុក-ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៨៦១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ កុយ-ឡាញ់ នាមឆាយា លញ្ញតេ្ករ កើតឆ្នាំមមី អាយុ ៤៤ វស្សា ២១ ជាចៅអធិការវត្តបាកាន ឃុំ-ស្រុក-ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៨៦២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ម៉ម-ទុក នាមឆាយា សុវណ្ណបញ្ញា កើតឆ្នាំមមី អាយុ ៦៨ វស្សា ៦ ជាគ្រូសូត្រស្តាំ វត្ត-ឃុំ-ស្រុក-ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៨៦៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ អ៊ុក-ខ្វា នាមឆាយា កលទូតេ្ករ កើតឆ្នាំម្សាញ់ អាយុ ៣៣ វស្សា ៣ ជាចៅអធិការវត្តកំបាំង ឃុំព្រះម្លូ ស្រុក-ខែត្រដដែល ។ (មានត)